# ការវិភាគស្ដីពីច្បាប់ស្ដីពីសហជីព និង ច្បាប់វិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និង មាត្រា៥៩នៃច្បាប់ស្ដីពីសហជីព

អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធមនុស្ស (CENTRAL)

ខែមករា ឆ្នាំ២០២០

# មាតិកា


១. សេចក្តីសង្ខេបនិងអនុសាសន៍ ..... 5

២. បុព្វកថា ..... 12

៣. មាត្រា ៣ ថ្មី – វិសាលភាព ..... 13

៤. មាត្រា ៥ – សិទ្ធិក្នុងការបង្កើត និងការចូលរួមនៅក្នុងសហជីព ឬសមាគមនិយោជក ..... 15

៥. មាត្រា ១០ – រចនាសម្ព័ន្ធសហជីព ឬសមាគមនិយោជក និងសម្ព័ន្ធភាពរវាងសហជីព ឬសមាគមនិយោជក ..... 16

៦. លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំចុះបញ្ជី ..... 18

៧. មាត្រា ១៣ – លក្ខខណ្ឌតម្រូវសម្រាប់លក្ខន្តិកៈ ..... 20

៨. មាត្រា ១៤ – អានុភាពនៃការចុះបញ្ជី ..... 22

៩. មាត្រា ១៥ – ចំណាត់ការនៅលើការដាក់ពាក្យសុំចុះបញ្ជី ..... 23

១០. មាត្រា ១៦ – ការពន្យារពេលការចុះបញ្ជី ..... 24

១១. មាត្រា ១៧ ថ្មី – ការរក្សាបញ្ជិកា និងមាត្រា ១៨ – ការជូនដំណឹងស្តីពីការកែតម្រូវ ..... 25

១២. មាត្រា ២០ ថ្មី – លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីពនៅក្នុងសហគ្រាសឬគ្រឹះស្ថាន ..... 27

១៣. មាត្រា ២១ ថ្មី – លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជក ..... 28

១៤. មាត្រា ២៤ – ការប្រើប្រាស់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិឱ្យស្របទៅតាមលក្ខន្តិកៈ និងច្បាប់ ..... 28

១៥. មាត្រា ២៧ ថ្មី – ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ ..... 30

១៦. មាត្រា ២៨ ថ្មី – ការរំលាយសហជីពឬសមាគមនិយោជក ............ 30

១៧. មាត្រា ២៩ ថ្មី – មូលហេតុនៃការរំលាយចោលដោយតុលាការការងារ ............ 32

១៨. មាត្រា ៣៨ – សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះជាបេក្ខជន ............ 34

១៩. មាត្រា ៤៣ – ការការពារប្រតិភូបុគ្គលិក ............ 35

២០. មាត្រា ៤៧ – បណ្ដឹងតវ៉ាទៅលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ............ 37

២១. មាត្រា ៥៤ ថ្មី – ភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន ............ 38

២២. មាត្រា ៥៥ ថ្មី – ភាពជាតំណាងបំផុតក្នុងវិជ្ជាជីវៈមួយឬសកម្មភាពសេដ្ឋកិច្ចមួយឬវិស័យមួយ ............ 40

២៣. មាត្រា ៥៦ – សំណើសុំបញ្ជាក់ភាពជាតំណាងបំផុត និងមាត្រា ៥៧ – ការកំណត់ភាពជាតំណាងបំផុតដោយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ 40

២៤. មាត្រា ៥៩ ថ្មី – សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាសឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុ 41

២៥. មាត្រា ៦២ – ការមិនរើសអើងដោយសារតែសកម្មភាពរបស់សហជីព និងមាត្រា ៦៣ – សកម្មភាពរបស់និយោជកដែលចាត់ទុកជាអនុវត្តមិនត្រឹមត្រូវ ............ 42

២៦. មាត្រា ៦៧ – ការការពារចំពោះការបញ្ឈប់ពីការងារ ............ 44

២៧. មាត្រា ៨៩ – អំពើបង្ខិតបង្ខំឱ្យចូលរួមធ្វើកូដកម្ម ............ 45

២៨. ជំពូកទី ១៥ – វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ ............ 46

២៩. ឯកសារយោង ............ 48

# បញ្ជីអក្សរកាត់

| | |
|---|---|
| AC | ក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| ACILS | អង្គការមជ្ឈមណ្ឌលអាមេរិកដើម្បីសាមគ្គីភាពការងារអន្តរជាតិ |
| C87 | អនុសញ្ញាស្តីពីសេរីភាពក្នុងការចូលរួមនិងការការពារសិទ្ធិក្នុងការចងក្រង ឆ្នាំ១៩៤៨ (លេខ ៨៧) |
| C98 | អនុសញ្ញាស្តីពីសិទ្ធិក្នុងការចងក្រងនិងចរចាអនុសញ្ញារួម ឆ្នាំ១៩៤៩ (លេខ ៩៨) |
| CATU | សហព័ន្ធសហជីពកម្ពុជា |
| CENTRAL | អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស |
| CEACR | គណៈកម្មាធិការនៃអ្នកជំនាញដើម្បីការអនុវត្តអនុសញ្ញានិងអនុសាសន៍ |
| CFA | គណៈកម្មាធិការស្តីពីសេរីភាពក្នុងការចូលរួម |
| CICA | សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា |
| CITA | សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ |
| FDC | កិច្ចសន្យាការងារដែលមានថិរវេលាកំណត់ |
| IDEA | សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| MoLVT | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MRS | ភាពជាតំណាងបំផុត |
| TUL | ច្បាប់ស្តីពីសហជីព(ឆ្នាំ២០១៦) |

# ១. សេចក្តីសង្ខេបនិងអនុសាសន៍

ការវិភាគ ស្តីអំពីច្បាប់ស្តីពីសហជីពនេះ (ឆ្នាំ២០១៦) និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩នៃច្បាប់ស្តីពីសហជីព ដែលបានប្រកាសឱ្យប្រើដោយរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ត្រូវបានរៀបចំដោយអង្គការ CENTRAL ដោយមានជំនួយបច្ចេកទេសពីអង្គការ ACILS ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ខែមករា ឆ្នាំ២០២០ ។ ការវិភាគនេះពិចារណាលើការស្នើសុំធ្វើវិសោធនកម្មបន្ថែមពីលើទៀតរបស់សហជីព ចាប់តាំងពីពេលដែលត្រូវបានបញ្ជូនទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងខែឧសភា និងខែសីហា ឆ្នាំ២០១៩កន្លងមក ។ ការវិភាគនេះផ្តល់អនុសាសន៍សម្រាប់ធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រាចំនួន ២៥ រួមបញ្ចូលជំពូកទី ១៥នៃច្បាប់ស្តីពីសហជីពដើម្បីឱ្យច្បាប់ស្របគ្នានឹងស្តង់ដារការងារអន្តរជាតិ ជាពិសេសអនុសញ្ញាលេខ C87 និង C98 ។ អនុសាសន៍សម្រាប់មាត្រានីមួយៗត្រូវបានរៀបរាប់នៅខាងក្រោម ។ សូមមើលផ្នែកពាក់ព័ន្ធសម្រាប់មាត្រានីមួយៗនៅក្នុងការវិភាគនេះសម្រាប់ ហេតុផលនៃអនុសាសន៍មួយៗនៃអនុសាសន៍ទាំងនេះ ។

## ១.១ មាត្រា ៣ – វិសាលភាព

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៣ ដើម្បីពង្រីកវិសាលភាពនៃច្បាប់ស្តីពីសហជីពដល់កម្មករទាំងអស់ដែលធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនគិតពីមុខរបររបស់ពួកគាត់លើកលែងតែអ្នកដែលធ្វើការជានគរបាល ឬកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះ ។

## ១.២ មាត្រា ៥ – សិទ្ធិក្នុងការបង្កើត និងការចូលរួមនៅក្នុងសហជីព ឬសមាគមនិយោជក

- ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌទី១ នៃមាត្រា ៥ ដូចតទៅ ៖ "ដោយគ្មានការប្រកាន់អ្វីទាំងអស់ កម្មករនិយោជិត និងនិយោជកមានសិទ្ធិបង្កើតសហជីព ឬសមាគមនិយោជកតាមការជ្រើសរើសរបស់ខ្លួន ។"

## ១.៣ មាត្រា ១០ – រចនាសម្ព័ន្ធសហជីព ឬសមាគមនិយោជក និងសម្ព័ន្ធភាពរវាងសហជីព ឬសមាគមនិយោជក

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ១០ ដើម្បីផ្តល់សិទ្ធិពិសេសជូនកម្មករធ្វើការតាមផ្ទះនិងកម្មករដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យពួកគាត់បង្កើតសហជីពដោយមានអ្នកស្ថាបនិកតិចជាងចំនួនអប្បបរមាដែលកំណត់ដោយច្បាប់ ឬឱ្យពួកគាត់ចូលជាសមាជិកសហជីពដោយផ្ទាល់តាមថ្នាក់វិស័យដូចបានស្នើអនុសាសន៍ដោយ CEACR ។

- ត្រូវមានបទប្បញ្ញត្តិដែលផ្តល់សិទ្ធិបង្កើតសហជីពជូនកម្មករដែលធ្វើការក្នុងសហគ្រាសឬគ្រឹះស្ថានដែលមានកម្មករតិចជាងចំនួនចំនួនអប្បបរមាកំណត់ដោយច្បាប់សម្រាប់ការបង្កើតសហជីព ។

## ១.៤ មាត្រា ១២ – លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំចុះបញ្ជី

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ១២ នៃច្បាប់ស្តីពីសហជីព និងប្រកាសលេខ ២៤៩/១៦ ដើម្បីធានាថាការស្នើសុំចុះបញ្ជីមិនតម្រូវឱ្យសហជីព ឬសមាគមនិយោជកទទួលការអនុញ្ញាតត្តិជាមុនពីអាជ្ញាធរ ។ ដូច្នេះ ត្រូវដកចេញលក្ខខណ្ឌតម្រូវការមួយចំនួនដូចជាអាសយដ្ឋានសម្រាប់ថែរក្សាទុកនូវសៀវភៅហិរញ្ញវត្ថុ និងកំណត់ត្រាហិរញ្ញវត្ថុ កិច្ចសន្យាធានាថានឹងផ្តល់រាល់ព័ត៌មានគណនីធនាគាររបស់ខ្លួនក្នុងរយៈពេល ៤៥ ថ្ងៃគិតពីថ្ងៃទទួលបានការចុះបញ្ជី កំណត់ហេតុច្បាប់ដើមនៃការបោះឆ្នោតបង្កើតអង្គការវិជ្ជាជីវៈ និងបញ្ជីរាយនាមកម្មករនិយោជិតទាំងអស់ដែលជាសមាជិកនៅក្នុងសហគ្រាស ឬគ្រឹះស្ថាន ។
- បន្ថែមពីនេះទៀត ត្រូវធ្វើវិសោធនកម្មលើប្រកាសលេខ ២៤៩/១៦ ដើម្បីដកចេញលក្ខខណ្ឌតម្រូវការពាក់ព័ន្ធការដាក់រូបថតនិងព័ត៌មានផ្ទាល់ខ្លួនរបស់ថ្នាក់ដឹកនាំសហជីព ហើយនិងសេចក្តីប្រកាសថាចេះអានចេះសរសេរអក្សរខ្មែរនិងមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋ ក៏ដូចជាធ្វើឱ្យមានលក្ខណៈផ្លូវការនូវការដកចេញលក្ខខណ្ឌតម្រូវការដាក់ព័ត៌មានអំពីគ្រួសាររបស់ថ្នាក់ដឹកនាំ ។

## ១.៥ មាត្រា ១៣ – លក្ខខណ្ឌតម្រូវសម្រាប់លក្ខន្តិកៈ

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៣ ដើម្បីដកចេញលក្ខខណ្ឌតម្រូវការដូចខាងក្រោម ៖
  - ការកំណត់ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុជាធម្មតា និងការបោះពុម្ពផ្សាយជាប្រចាំនូវរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់សហជីព ឬសមាគមនិយោជក ;
  - ការកំណត់ចំនួនកូរ៉ុមប្រជុំចំនួនភាគច្រើនដាច់ខាត (ចំនួនយ៉ាងតិច ៥០%+១) នៃសមាជិកសហជីពសរុបសម្រាប់រាល់កិច្ចប្រជុំសម្រេចធ្វើកូដកម្ម កែប្រែលក្ខន្តិកៈ និងមហាសន្និបាតរបស់សហជីព ;
  - លក្ខខណ្ឌតម្រូវឱ្យមានការបោះឆ្នោតជាសម្ងាត់ដោយសំឡេងយ៉ាងតិច ៥០%+១ នៃសមាជិកដែលចូលរួមកិច្ចប្រជុំសម្រេចធ្វើកូដកម្ម ;
  - ការកំណត់ចំនួនប្រាក់ភាគទានដែលសមាជិកម្នាក់ៗត្រូវតែបង់និងបែបបទនៃការបង់ប្រាក់ភាគទានប្រចាំខែត្រូវកំណត់ដោយមហាសន្និបាត ឬសន្និបាតរបស់សហជីព ;
  - លក្ខណសម្បត្តិសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលយ៉ាងហោចណាស់ឱ្យស្របតាមមាត្រា ២០ និង មាត្រា ២១ នៃច្បាប់ស្តីពីសហជីព ។
- ត្រូវដកចេញប្រការ ៣ នៃប្រកាសលេខ ២៤៩/១៦ នូវលក្ខខណ្ឌតម្រូវស្រដៀងគ្នានឹងលក្ខខណ្ឌតម្រូវការខាងលើនេះ

- ត្រូវធ្វើវិសោធនកម្មលើប្រកាសលេខ ២៤៩/១៦ ផងដែរ ដើម្បីឱ្យច្បាស់លាស់ថាលក្ខន្តិកៈគំរូនៅក្នុងឧបសម្ព័ន្ធទី២នៃប្រកាសមិនមែនជាកាតព្វកិច្ចសម្រាប់សហជីព ឬសមាគមនិយោជកប្រើប្រាស់ទេ ។

## ១.៦ មាត្រា ១៤ – អានុភាពនៃការចុះបញ្ជី

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៤ យោងតាមការស្នើសុំរបស់សហជីពដោយផ្តល់បុគ្គលភាពគតិយុត្ត និងសិទ្ធិក្នុងការធ្វើសកម្មភាពនិងប្រតិបត្តិការជាទូទៅជូនសហជីពចាប់ពីថ្ងៃជូនដំណឹងដល់និយោជកអំពីការបោះឆ្នោតបង្កើតសហជីព ។

## ១.៧ មាត្រា ១៥ – ចំណាត់ការនៅលើការដាក់ពាក្យសុំចុះបញ្ជី

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៥ និង/ឬ ប្រកាសលេខ ២៤៩/១៦ ដើម្បីបញ្ជាក់ឱ្យច្បាស់លាស់ថាគំរូដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសមិនមែនជាកាតព្វកិច្ចសម្រាប់ការប្រើប្រាស់សម្រាប់សហជីពនិងសមាគមនិយោជកឡើយ ។

## ១.៨ មាត្រា ១៦ – ការពន្យារពេលការចុះបញ្ជី

- ត្រូវដកចេញកថាខណ្ឌ ឃ និង ង ។

## ១.៩ មាត្រា ១៧ – ការរក្សាបញ្ជិកា និងមាត្រា ១៨ – ការជូនដំណឹងស្តីពីការកែតម្រូវ

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៧ យោងតាមការស្នើសុំរបស់សហជីពដោយតម្រូវ ឱ្យតែសហជីពរៀបចំរបាយការណ៍សកម្មភាពនិងហិរញ្ញវត្ថុប្រចាំឆ្នាំតាមទម្រង់ដែលកំណត់ដោយផ្ទាល់ដើម្បីឱ្យសមាជិករបស់ខ្លួនបានជ្រាបជាព័ត៌មានប៉ុណ្ណោះ ។
- ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៨ ដោយដកសមត្ថភាពរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការប្តឹងទៅតុលាការការងារដើម្បីលុបបញ្ជិការបស់សហជីពនៅពេលដែលមិនបានអនុវត្តតាមមាត្រា ១៧ និងជំនួសដោយការពិន័យក្នុងករណីដែលសហជីពនៅតែមិនអនុវត្តតាមការជូនដំណឹងជាមួយនឹងការដាស់តឿនដូចចែងក្នុងមាត្រានេះរួចហើយ ។

## ១.១០ មាត្រា ២០ – លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីពនៅក្នុងសហគ្រាស ឬគ្រឹះស្ថាន

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២០ យោងតាមការស្នើរបស់ CEACR ដោយដកចេញការតម្រូវការអាយុអប្បបរមា និងការធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅច្បាស់លាស់ចំពោះពលរដ្ឋខ្មែរ ។

- ត្រូវដកចេញការតម្រូវការអាយុអប្បបរមា និងការតម្រូវការចេះអានចេះសរសេរចំពោះជនបរទេស ។

## ១.១១ មាត្រា ២១ – លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជក

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២១ ដូចមាត្រា ២០ យោងតាមការរកឃើញរបស់ខាង CEACR ដោយដកចេញការតម្រូវការអាយុនិងអាសយដ្ឋានចំពោះពលរដ្ឋខ្មែរ ព្រមទាំងការតម្រូវការអាយុចំពោះជនបរទេស ។

## ១.១២ មាត្រា ២៤ – ការប្រើប្រាស់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិឱ្យស្របទៅតាមលក្ខន្តិកៈ និងច្បាប់

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ២៤ (ឬលើមាត្រា ៤ – និយមន័យ)ដើម្បីកំណត់អោយច្បាស់លាស់ថាអ្នកណាជា "ភាគីពាក់ព័ន្ធ" ។ និយមន័យនេះគួរកំណត់ដើម្បីធានាថាមានតែភាគីពិតប្រាកដជាអ្នកពាក់ព័ន្ធ (ឧទាហរណ៍ សមាជិកសហជីពឬសមាគមនិយោជក) ដែលមានសិទ្ធិស្នើសុំធ្វើសវនកម្មតាមមាត្រា ២៤ ហើយមិនមែនជាភាគីដែលមានការទំនាក់ទំនងតែមួយមុខគត់ក្នុងការប្រើប្រាស់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សហជីពឬសមាគមនិយោជក ។

## ១.១៣ មាត្រា ២៧ – ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២៧ ដែលស្រដៀងគ្នានឹងមាត្រា ១៧ ដោយតម្រូវឱ្យសហជីពនិងសមាគមនិយោជកថែរក្សាកំណត់ត្រាហិរញ្ញវត្ថុតាមទម្រង់កំណត់ដោយផ្ទាល់ គោលបំណងដើម្បីឱ្យសមាជិករបស់ខ្លួនបានជ្រាបជាព័ត៌មាន ។

## ១.១៤ មាត្រា ២៨ – ការរំលាយសហជីព ឬសមាគមនិយោជក

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២៨ យោងតាមការកំណត់សម្គាល់របស់ខាង CEACR ដោយដកចេញកថាខណ្ឌទីពីរដើម្បីធានាថាការរំលាយសហជីពត្រូវតែកើតឡើងតាមនីតិវិធីរបស់ខ្លួនដូចកំណត់ដោយលក្ខន្តិកៈរបស់សហជីព ឬដោយសេចក្តីសម្រេចរបស់តុលាការប៉ុណ្ណោះ ។
- រាជរដ្ឋាភិបាលក៏គួរពិចារណាធ្វើវិសោធនកម្មលើកថាខណ្ឌទីបីនៃមាត្រា ២៨ (រួមជាមួយមាត្រា ២៩) ដើម្បីផ្តល់អំណាចជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការរំលាយសហជីពជំនួសឱ្យសាលាដំបូង ។

## ១.១៦ មាត្រា ២៩ – មូលហេតុនៃការរំលាយចោលដោយតុលាការការងារ

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២៩ ដើម្បីឱ្យពាក្យពេចន៍កថាខណ្ឌ ក និង ខ មានភាពច្បាស់លាស់ជាងមុន ។

- ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌ ក ដើម្បីធានាថាការបំពានតូចតាចមិនបណ្តាលឱ្យមានការរំលាយចោលសហជីពឬសមាគមនិយោជក ហើយការរំលាយចោលជាជម្រើសចុងក្រោយបន្ទាប់ពីមានការរំលោភច្បាប់ដ៏ធ្ងន់ធ្ងរ ។
- ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌ ខ ដើម្បីឱ្យមានភាពច្បាស់លាស់ជាងមុន ជាពិសេសទាក់ទងនឹងនិយមន័យនៃមិនមានលក្ខណៈឯករាជ្យពីនិយោជក ហើយក៏ដូចជាករណីដែលត្រូវកើតមានដើម្បីឱ្យរកឃើញថាសហជីពនោះមិនអាចស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួន ។
- ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌ ខ ដើម្បីឱ្យតុលាការរំលាយចោលសហជីពដែលមិនមានលក្ខណៈឯករាជ្យពីរដ្ឋាភិបាលក្នុងករណីសហជីពនោះជាក់ស្តែងមិនអាចស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួន ។
- ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌចុងក្រោយនៃមាត្រា ២៩ ដោយកំណត់ពេលវេលាសម្រាប់ការធ្វើការកែតម្រូវកង្វះខាតទាំងឡាយដូចមានចែងក្នុងកថាខណ្ឌ ក និង ខ ។

## ១.១៦ មាត្រា ៣៨ – សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះជាបេក្ខជន

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ៣៨ ដោយដកចេញតម្រូវការអាយុអប្បបរមា ចេះអានចេះសរសេរ និងអតីតភាពការងារដែលកំពុងកំណត់ដោយមាត្រានេះ ។

## ១.១៧ មាត្រា ៤៣ – ការការពារប្រតិភូបុគ្គលិក

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ៤៣ យោងតាមការស្នើសុំរបស់សហជីពដោយផ្តល់អំណាចជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការដោះស្រាយការតវ៉ាទៅនឹងសេចក្តីសម្រេចរបស់អធិការការងារដើម្បីធ្វើឱ្យនីតិវិធីដំណោះស្រាយលឿននិងសាមញ្ញសម្រាប់ករណីការបញ្ឈប់ប្រតិភូបុគ្គលិក ។

## ១.១៨ មាត្រា ៤៧ – បណ្តឹងតវ៉ាទៅលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ៤៧ ដោយផ្តល់សិទ្ធិជូនកម្មករនិងសហជីពក្នុងការដាក់ពាក្យបណ្តឹងទៅលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក សិទ្ធិឈរឈ្មោះ និងភាពមិនត្រឹមត្រូវនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកជូនមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្រុងនិងខេត្ត ។ ក្នុងករណីដែលបញ្ហានេះមិនអាចដោះស្រាយបានដោយការផ្សះផ្សា វិវាទទាំងនេះត្រូវបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

## ១.១៩ មាត្រា ៥៤ – ភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៥៤ ដោយដកចេញសិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទរួម។

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៥៤ និងប្រកាសលេខ ៣០៣/១៨ ដោយដកចេញលក្ខខណ្ឌតម្រូវការក្នុងការដាក់បញ្ជីឈ្មោះសមាជិក ។
- ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌ គ នៃមាត្រា ៥៤ រួមទាំងប្រការពាក់ព័ន្ធនៅក្នុងប្រកាសលេខ ៣០៣/១៨ ដើម្បីតម្រូវឱ្យនិយោជករៀបចំការបោះឆ្នោតស្វែងរកការគាំទ្រពីកម្មករនិយោជិតសរុបក្នុងសហគ្រាស ឬគ្រឹះស្ថានគោលបំណងដើម្បីស្វែងរកសហជីពដែលពិតជាមានការគាំទ្រពីកម្មករ ។

## ១.២០ មាត្រា ៥៥ – ភាពជាតំណាងបំផុតនៅក្នុងវិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ ឬវិស័យមួយ

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៥៥ ដោយដកចេញសិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួម និងលក្ខខណ្ឌតម្រូវការដាក់បញ្ជីឈ្មោះសមាជិកដែលបានកាត់ប្រាក់ភាគទាន ។

## ១.២១ មាត្រា ៥៦ – សំណើសុំបញ្ជាក់ភាពជាតំណាងបំផុត និងមាត្រា ៥៧ – ការកំណត់ភាពជាតំណាងបំផុតដោយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ៥៦ និងមាត្រា ៥៧ ដោយផ្ទេរកាតព្វកិច្ចបញ្ជាក់ភាពជាតំណាងបំផុតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈជូនស្ថាប័នឯករាជ្យដូចជាក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

## ១.២២ មាត្រា ៥៩ – សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស ឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុត

- ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៥៩ ដោយផ្តល់សិទ្ធិជូនសហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស ឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុតក្នុងការធ្វើជាតំណាងសមាជិករបស់ខ្លួនក្នុងវិវាទបុគ្គលនិងរួម ។

## ១.២៣ មាត្រា ៦២ – ការមិនរើសអើងដោយសារតែសកម្មភាពរបស់សហជីព និងមាត្រា ៦៣ – សកម្មភាពរបស់និយោជកដែលចាត់ទុកថាអនុវត្តមិនត្រឹមត្រូវ

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ៦២ និងមាត្រា ៦៣ ដោយផ្តល់ការការពារបន្ថែមទៀតជូនសមាជិកសកម្មជន និងថ្នាក់ដឹកនាំសហជីពដែលមានកិច្ចសន្យាការងារដែលមានថិរវេលាកំណត់ដើម្បីឆ្លើយតបទៅនឹងការព្រួយបារម្ភដែល CFA បានលើកឡើងនៅក្នុងករណីពាក់ព័ន្ធនឹងប្រទេសកម្ពុជាប្រើប្រាស់កិច្ចសន្យាការងារបែបនេះក្នុងរយៈពេលវែងក្នុងគោលបំណងធ្វើអោយមានចុះខ្សោយនិងរារាំងសហជីព ។
- ច្បាប់អាចផ្តល់ការការពារនេះដោយផ្ទេរបន្ទុកនៃការបង្ហាញភស្តុតាងក្នុងករណីមិនបន្តកិច្ចសន្យាពីកម្មករនិយោជិតទៅនិយោជកនិងតម្រូវឱ្យនិយោជកផ្តល់ភស្តុតាងបង្ហាញវិញថាកិច្ចសន្យាការងាររបស់កម្ម

ករនិយោជិតគឺមិនត្រូវបានបន្តសារជាថ្មីដោយសារមូលហេតុក្រៅពីជាសមាជិកឬការចូលរួមក្នុងសកម្មភាពសហជីព ។

## ១.២៤ មាត្រា ៦៧ – ការការពារចំពោះការបញ្ឈប់ពីការងារ

- ត្រូវធ្វើវិសោធនកម្មលើមាត្រា ៦៧ ដើម្បីតម្រូវឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈចាត់វិធានការកាន់តែខ្លាំងដើម្បីអនុវត្តសេចក្តីសម្រេចរបស់ខ្លួនក្រោយពីបង្គាប់ឱ្យនិយោជកទទួលយកកម្មករចូលធ្វើការវិញ ។
- ត្រូវធ្វើវិសោធនកម្មលើមាត្រា ៦៧ ដើម្បីផ្តល់ការការពារកាន់តែច្រើនឡើងក្នុងករណីមិនបន្តកិច្ចសន្យាការងារដោយរើសអើងសហជីពចំពោះកម្មករនិយោជិតដែលមានកិច្ចសន្យាការងារដែលមានថិរវេលាកំណត់ ។

## ១.២៥ មាត្រា ៨៩ - អំពើបង្ខិតបង្ខំឱ្យចូលរួមធ្វើកូដកម្ម

- ត្រូវលុបចោលមាត្រានេះ ឬធ្វើវិសោធនកម្មដោយមាត្រានេះសំដៅតែ កូដកម្មខុសច្បាប់ និង/ឬកូដកម្មប្រកបដោយអំពើហឹង្សា ។

## ១.២៦ ជំពូកទី ១៥ – វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ

- ត្រូវបង្កើនពិន័យនៅក្រោមជំពូកទី ១៥ ដើម្បីឱ្យមានពិន័យដែលមានប្រសិទ្ធិភាពក្នុងការកាត់បន្ថយករណីរើសអើងសហជីព ជាពិសេសមាត្រា ៧៩ (អំពើរាំងដោយខុសច្បាប់នូវសិទ្ធិបង្កើតសហជីព ឬសមាគមនិយោជក ជាអាទិ៍) មាត្រា ៨២ (អំពើបំពានកាតព្វកិច្ចក្នុងការរៀបចំបោះឆ្នោត) មាត្រា ៨៤ (ការធ្វើសកម្មភាពដោយមិនសុចរិត និងស្មោះត្រង់) មាត្រា ៨៧ (អំពើរាំងដោយខុសច្បាប់នូវការធ្វើកូដកម្ម) មាត្រា ៨៨ (អំពើប្រឆាំងនឹងការផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការអនុវត្តច្បាប់ការងារជាអាទិ៍) មាត្រា៩៣ (ឡុកអៅដោយខុសច្បាប់) និងមាត្រា៩៤ (ការទទួលខុសត្រូវរបស់សមាគមនិយោជក) ។
- ត្រូវបង្កើតពិន័យថ្មីសម្រាប់ការរំលោភទៅលើមាត្រា ៦២ និង ៦៣ នៃច្បាប់ស្តីពីសហជីព ។

## ២. បុព្វកថា

២.១ ច្បាប់ស្តីពីសហជីពបានធ្វើសេចក្តីព្រាងជាដំបូងនៅក្នុងឆ្នាំ ២០០៨ ហើយបានពិភាក្សាក្នុងរយៈពេល ៨ ឆ្នាំរហូតដល់បានប្រកាសឱ្យប្រើនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៦ ។ មុនការអនុម័តច្បាប់ស្តីពីសហជីព បទប្បញ្ញត្តិស្តីពីសហជីពភាគច្រើនត្រូវបានកំណត់ដោយច្បាប់ស្តីពីការងារ ។[1]

២.២ ច្បាប់ស្តីពីសហជីពគឺមានភាពចម្រូងចម្រាសនៅក្នុងប្រទេសកម្ពុជា ។ អង្គការពលម្មអន្តរជាតិបានរិះគន់ច្បាប់ដោយប្រយ័ត្នប្រយែងមុនពេលច្បាប់អនុម័តដោយរដ្ឋសភាជាតិ ហើយបានស្នើសុំវិសោធនកម្មមួយចំនួនដូចជាការពង្រីកវិសាលភាពច្បាប់ទៅនឹងកម្មករធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនិងមន្ត្រីរាជការ ព្រមទាំងការដកចេញការម្រូវអាយុ អាសយដ្ឋាន និងចេះអានចេះសរសេរសម្រាប់ថ្នាក់ដឹកនាំសហជីព ។[2] នៅថ្ងៃដែលរដ្ឋសភាជាតិបានបោះឆ្នោតលើច្បាប់ស្តីពីសហជីព បាតុករប្រមាណ ១០០ នាក់ដែលមកពីសហជីពបានប៉ះទង្គិចជាមួយសន្តិសុខនៅខាងមុខអគាររដ្ឋសភាជាតិដោយមានយ៉ាងហោចមនុស្ស ២ នាក់បានរងរបួស ។[3] សរុបទៅ ច្បាប់បានអនុម័តដោយមានសំឡេង ៦៧ ទល់នឹងសំឡេង ៣១ ។[4]

២.៣ នៅពេលអនុម័ត ច្បាប់ស្តីពីសហជីពត្រូវបានទទួលការរិះគន់ពីអង្គការធ្វើការលើសិទ្ធិមនុស្សនិងសិទ្ធិការងារដែលថាច្បាប់នេះផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញនិងស្តង់ដារការងារអន្តរជាតិ ។[5] ចំណែកឯសហជីពបានលើកឡើងថាពួកគេមានអារម្មណ៍ថាច្បាប់ស្តីពីសហជីពផ្តល់អំណាចច្រើនពេកជូនរដ្ឋាភិបាលទាក់ទងនឹងសកម្មភាពសហជីព និងរារាំងកម្លាំងពលកម្មមួយចំនួនពីការការពារដោយច្បាប់ ហើយក៏បានលើកឡើងការព្រួយបារម្ភរបស់ខ្លួនថាច្បាប់ស្តីពីសហជីពរារាំងសិទ្ធិក្នុងការធ្វើកូដកម្ម និងដាក់នីតិវិធីការចុះបញ្ជីនិងការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុស្មុគស្មាញពេក ។[6] ក៏មានអ្នកពាក់ព័ន្ធមួយចំនួនក្រៅពីអង្គការសិទ្ធិមនុស្សនិងសហជីពដែលបានអំពាវនាវដល់រដ្ឋាភិបាលឱ្យមានការធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពដូចជាក្រុមហ៊ុនបញ្ជាទិញវិស័យកាត់ដេរនិងស្បែកជើង[7] ហើយក្រុមហ៊ុនបញ្ជាទិញផ្សេងៗ[8] ។ តាំងពីថ្ងៃអនុម័ត ច្បាប់ស្តីពីសហជីពត្រូវបានលើកឡើងថាជាកត្តារួមចំណែកដ៏សំខាន់ក្នុងការការកាត់បន្ថយចំនួនកូដកម្ម និងសេចក្តីបង្គាប់ចេញពីក្រុមប្រឹក្សាអាជ្ញាកណ្តាល[9]។ ឧទាហរណ៍នៅក្នុងឆ្នាំ ២០១៥ មុនការប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ចំនួន ២៤២ សំណុំរឿង ។[10] ចំនួនសំណុំរឿងនេះបានកាត់បន្ថយសល់ត្រឹម ២១៩ ករណីនៅក្នុងឆ្នាំ ២០១៦[11] មុននឹងធ្លាក់ចុះដល់ ៥០ សំណុំរឿងនៅក្នុងឆ្នាំ២០១៧ និង ៤១ សំណុំរឿងនៅក្នុងឆ្នាំ ២០១៨ ។[12] ប៉ុន្តែអ្វីដែលគួរកត់សម្គាល់ នៅក្នុងឆ្នាំ២០១៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ចំនួនលើសពី ១០០ សំណុំរឿង ។

២.៤ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានប្រកាសថានឹងមានការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសហជីព ។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេ

ចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មលើមាត្រា ៣ មាត្រា ១៧ មាត្រា ២០ មាត្រា២១ មាត្រា ២៧ មាត្រា ២៨ មាត្រា ២៩ មាត្រា ៥៤ មាត្រា ៥៥ និងមាត្រា៥៩នៃច្បាប់ស្តីពីសហជីព ។ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំកិច្ចប្រជុំត្រីភាគីរវាងសហជីព មន្ត្រីរដ្ឋាភិបាល និងតំណាងនិយោជកដើម្បីពិភាក្សាអំពីសេចក្តីព្រាងច្បាប់នេះ ។ ក្រោយពីក្រសួងបានចេញសេចក្តីព្រាងច្បាប់នេះ សហជីពបានផ្ញើពីរលិខិតជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងខែឧសភានិងមេសាដែលបានស្នើសុំការវិសោធនកម្មបន្ថែមទៀតលើមាត្រាដែលត្រូវបានវិសោធនកម្មដោយសេចក្តីព្រាងច្បាប់ រួមបញ្ចូលការវិសោធនកម្មទៅនឹងមាត្រា ១០ មាត្រា ១៤ មាត្រា ៤៣ មាត្រា ៤៧ និងមាត្រា ៦៧[13] ប៉ុន្តែការដាក់ស្នើទាំងនោះក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមិនបានទទួលយកទេ ។

២.៥ នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជូនសេចក្តីព្រាងច្បាប់វិសោធនកម្មលើកទី២ទៅគណៈរដ្ឋមន្ត្រី ។ នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ រដ្ឋសភាជាតិបានបោះឆ្នោតឱ្យអនុម័តសេចក្តីព្រាងច្បាប់នេះដោយគ្មានការផ្លាស់ប្តូរ ហើយនៅថ្ងៃទី ៩ ខែធ្នូ ឆ្នាំ២០១៩ ព្រឹទ្ធសភាក៏បានបោះឆ្នោតឱ្យអនុម័តសេចក្តីព្រាងច្បាប់នេះដោយគ្មានការផ្លាស់ប្តូរផងដែរ ។ នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានពិនិត្យមើល ហើយអនុម័តសេចក្តីព្រាងច្បាប់នេះ ។ វិសោធនកម្មទាំងនេះត្រូវបានទទួលការរិះគន់ពីអង្គការសិទ្ធិមនុស្សនិងសហជីពដែលលើកឡើងថាច្បាប់នេះនៅតែមិនស្របទៅតាមស្តង់ដារការងារអន្តរជាតិ និងមិនដោះស្រាយបញ្ហាមួយចំនួន ។[14] ច្បាប់វិសោធនកម្មនេះត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ៣ ខែមករាឆ្នាំ ២០២០ ។ នៅពេលបានចេញរបាយការណ៍ក្រោយពីធ្វើការស៊ើបអង្កេតអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាពីប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធ គណៈកម្មការសហភាពអឺរ៉ុបក៏បានអំពាវនាវដល់រដ្ឋាភិបាលឱ្យរៀបចំការចរចាសារជាថ្មីជាមួយនឹងដៃគូសង្គមដើម្បីបន្តវិសោធនកម្មច្បាប់ស្តីពីសហជីព ។[15]

## ៣. មាត្រា ៣ ថ្មី – វិសាលភាព

៣.១ ច្បាប់វិសោធនកម្មដកចេញនូវកថាខណ្ឌទី ២ នៃមាត្រា ៣ និងកែប្រែបន្តិចបន្តួចពាក្យនៃកថាខណ្ឌទី ១ ដែលបញ្ជាក់ថាច្បាប់ស្តីពីសហជីពគ្របដណ្តប់លើគ្រឹះស្ថាន សហគ្រាសនិងបុគ្គលទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ នេះគឺជាការចាកចេញយ៉ាងសំខាន់ពីអ្វីដែលត្រូវបានរួមបញ្ចូលនៅក្នុងសេចក្តីព្រាងវិសោធនកម្មដែលបានពង្រីកវិសាលភាពចំពោះអ្នកធ្វើការតាមផ្ទះ។ លើសពីនេះទៀតការធ្វើវិសោធនកម្មបានដកបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រពីការគ្របដណ្តប់ដោយច្បាប់។

៣.២ មាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីពនិងចូលជាសមាជិកសហជីពនេះ"។" លើសពីនេះទៀត មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថាប្រជាពលរដ្ឋខ្មែរ "មានភាពស្មើគ្នាចំពោះមុខច្បាប់" និងមានសិទ្ធិសេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ ដោយមិនគិតពីស្ថានភាពរបស់ពួកគាត់ ។

៣.៣ មាត្រា ២ នៃ C87 ចែងថាកម្មករនិយោជិតទាំងអស់មានសិទ្ធិក្នុងការបង្កើតអង្គការតាមជម្រើសរបស់ពួកគាត់ ដោយគ្មានការប្រកាន់អ្វីទាំងអស់។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ហើយដូច្នេះមានកាតព្វកិច្ចក្នុងការអនុវត្ត ។ កាតព្វកិច្ចនេះត្រូវបានឆ្លុះបញ្ចាំងដោយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញដែលចែងថាប្រទេសកម្ពុជា "ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុង ... កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស" ។ នៅក្នុងឆ្នាំ ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ថាកតិកាសញ្ញានិងអនុសញ្ញាទាំងនេះអាចយកមកអនុវត្តចំពោះច្បាប់ក្នុងស្រុករបស់កម្ពុជា ។[16]

៣.៤ នៅក្នុងឆ្នាំ ២០១៧ គណៈកម្មាធិការជំនាញស្តីពីការអនុវត្តអនុសញ្ញានិងអនុសាសន៍ (CEACR) បានអំពាវនាវដល់រាជរដ្ឋាភិបាលឱ្យធ្វើវិសោធនកម្មលើច្បាប់ស្តីពីសហជីពដើម្បីផ្តល់សិទ្ធិក្នុងការបង្កើតសមាគមយោងតាមអនុសញ្ញា C87 ជូនមន្រ្តីរាជការ (រួមបញ្ចូលគ្រូបង្រៀន) ហើយក៏ផ្តល់សិទ្ធិបែបនេះជូនកម្មករដែលធ្វើការតាមផ្ទះនិងកម្មករដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។[17] គណៈកម្មាធិការស្តីពីសេរីភាពក្នុងការចូលរួមសមាគម (CFA) ក៏បានលើកឡើងថាមន្រ្តីរាជការ គ្រូបង្រៀន ចៅក្រម អ្នកធ្វើការដឹកជញ្ជូនតាមផ្លូវអាកាសនិងតាមសមុទ្រ និងកម្មករធ្វើការតាមផ្ទះនៅក្នុងប្រទេសកម្ពុជាគួរមានសិទ្ធិសេរីភាពក្នុងការបង្កើតសហជីព ។[18]

៣.៥ យោងតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញនិងអនុសញ្ញា C87 មាត្រា ៣ នៃច្បាប់ស្តីពីសហជីពនៅតែត្រូវការធ្វើវិសោធនកម្មបន្ថែមទៀត ។ មាត្រា ៣ ដែលត្រូវបានធ្វើវិសោធនកម្មនៅតែមិនរាប់បញ្ចូលប្រភេទមុខរបរមួយចំនួនដែលច្បាប់គ្របដណ្តប់ ដូចជាមន្រ្តីរាជការ (រួមទាំងគ្រូបង្រៀន វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា) បុគ្គលិកវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ(ឧទាហរណ៍អ្នកលក់តាមផ្សារ អ្នករត់ម៉ូតូឌុប និងអ្នកលក់តាមផ្លូវ) ប៉ូលីស សមាជិកកងកម្លាំងប្រដាប់អាវុធ សមាជិកវិជ្ជាជីវៈតុលាការ ហើយឥឡូវនេះអ្នកធ្វើការតាមផ្លូវអាកាសនិងតាមនាវាសមុទ្រផងដែរ។ចំពោះប៉ូលីស និងកងកម្លាំងប្រដាប់អាវុធ បើសិនជាច្បាប់មិនគ្របដណ្តប់ពួកគាត់ មិនមានន័យថាច្បាប់នេះរំលោភស្តង់ដារការងារអន្តរជាតិទេ ដោយសារមាត្រា ៩ នៃអនុសញ្ញា C87 ចែងថា "ច្បាប់ ឬបទប្បញ្ញត្តិក្នុងស្រុកត្រូវកំណត់ពីវិសាលភាពនៃការធានាដែលផ្តល់ដោយអនុសញ្ញានេះចំពោះកងកម្លាំងប្រដាប់អាវុធ និងនគរបាល ។"

*អនុសាសន៍ ៖*

៣.៦ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៣ ដើម្បីពង្រីកវិសាលភាពនៃច្បាប់ស្តីពីសហជីពដល់កម្មករទាំងអស់ដែលធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនគិតពីមុខរបររបស់ពួកគាត់លើកលែងតែអ្នកដែលធ្វើការជានគរបាល ឬកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះ ដូច្នេះច្បាប់នេះនឹងអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងមាត្រា២នៃC87។

## ៤. មាត្រា ៥ – សិទ្ធិក្នុងការបង្កើត និងការចូលរួមនៅក្នុងសហជីព ឬសមាគមនិយោជក

៤.១ មាត្រា ៥ នៃច្បាប់ស្តីពីសហជីពចែងថា ដោយគ្មានការប្រកាន់អ្វីទាំងអស់ កម្មករនិយោជិតនិងនិយោជកមានសិទ្ធិបង្កើតសហជីព ឬសមាគមនិយោជកតាមការជ្រើសរើសរបស់ខ្លួន ក្នុងគោលបំណងសម្រាប់តែការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការលើកតម្កើងផលប្រយោជន៍ និងការការពារសិទ្ធិក៏ដូចជាផលប្រយោជន៍ផ្នែកស្មារតី និងសម្ភារជាសមូហភាព និងជាឯកត្តជនចំពោះបុគ្គលដែលលក្ខន្តិកៈរបស់សហជីព ឬសមាគមនិយោជកនោះបានកំណត់ ។

៤.២ ពាក្យ "ក្នុងគោលបំណងសម្រាប់តែ" ដូចចែងក្នុងមាត្រា ៥ រារាំងសហជីព និងសមាគមនិយោជកពីគោលបំណងណាមួយក្រៅពីគោលបំណងដែលចែងក្នុងមាត្រា ៥ ។ មាត្រា ២ នៃអនុសញ្ញា C87 ចែងថា "ដោយគ្មានការប្រកាន់អ្វីទាំងអស់ កម្មករនិយោជិតនិងនិយោជកមានសិទ្ធិក្នុងការបង្កើត ... អង្គការតាមការជ្រើសរើសរបស់ខ្លួនដោយមិនត្រូវការការអនុញ្ញាតតជាមុន ។" លើសពីនេះទៀត មាត្រា ៣ នៃអនុសញ្ញា C87 ចែងថា "អង្គការនានារបស់កម្មករនិយោជិតនិងនិយោជកមានសិទ្ធិក្នុងការរៀបចំលក្ខន្តិកៈនិងច្បាប់ ... ការរៀបចំរដ្ឋបាល និងការរៀបចំសកម្មភាពរបស់ខ្លួន និងដើម្បីបង្កើតកម្មវិធីរបស់ពួកគេ ។"

៤.៣ មាត្រា ៥ គឺផ្ទុយទៅនឹងមាត្រា ២ និងមាត្រា ៣ នៃអនុសញ្ញា C87 ដោយត្រូវផ្តល់បញ្ជីគោលបំណងដែលសហជីពនិងសមាគមនិយោជកអាចអនុវត្ត ។ យោងតាមអនុសញ្ញា C87 អង្គការនានារបស់កម្មករនិយោជិតនិងនិយោជកមានសិទ្ធិក្នុងការដាក់ក្នុងលក្ខន្តិកៈរបស់ខ្លួននូវគោលបំណងសន្តិវិធីដែលគេគិតថាជាចាំបាច់ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់សមាជិករបស់ខ្លួន ។[19]

*អនុសាសន៍ ៖*

៤.៤ ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌទី១ នៃមាត្រា ៥ ដូចតទៅ ៖ "ដោយគ្មានការប្រកាន់អ្វីទាំងអស់ កម្មករនិយោជិត និងនិយោជកមានសិទ្ធិបង្កើតសហជីព ឬសមាគមនិយោជកតាមការជ្រើសរើសរបស់ខ្លួន ។"

## ៥. មាត្រា ១០ – រចនាសម្ព័ន្ធសហជីព ឬសមាគមនិយោជក និងសម្ព័ន្ធភាពរវាងសហជីព ឬសមាគមនិយោជក

៥.១ មាត្រា ១០ នៃច្បាប់ស្តីពីសហជីពមិនត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះទេ ។ នៅក្នុង លិខិតពីរដែលបានផ្ញើជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហជីពនិងសមាគមបានស្នើសុំធ្វើវិសោធនកម្មលើមាត្រា ១០ ផងដែរ ប៉ុន្តែហាក់ដូចជាក្រសួងមិនបានពិចារណាលើការស្នើសុំនោះទេ ។

៥.២ មាត្រា ១០ នៃច្បាប់ស្តីពីសហជីពកំណត់ចំនួនសមាជិកអប្បបរមាដែលចាំបាច់សម្រាប់រចនាសម្ព័ន្ធសហជីព ៣ ថ្នាក់ គឺសហជីពមូលដ្ឋាន សហព័ន្ធសហជីព និងសហភាពសហជីព ។ យោងតាមគំរូសហជីពសហគ្រាសដែលកំណត់ដោយច្បាប់ស្តីពីសហជីព ត្រូវមានកម្មករនិយោជិតយ៉ាងហោច ១០ នាក់ដើម្បីបង្កើតសហជីពមូលដ្ឋាននៅក្នុងសហគ្រាស ឬគ្រឹះស្ថាន ។ ទន្ទឹមនឹងនេះដែរ ត្រូវមានសហជីពមូលដ្ឋានយ៉ាងហោច ៧ សហជីពដែលមានបញ្ជិកា រួចហើយដើម្បីបង្កើតសហព័ន្ធសហជីព ហើយសហព័ន្ធសហជីពយ៉ាងហោច ៥ សហព័ន្ធដែលមានបញ្ជិកដើម្បីបង្កើតសហភាពការងារ ។

៥.៣ ក្រុមសហជីពបានស្នើសុំការធ្វើវិសោធនកម្មលើលក្ខខណ្ឌតម្រូវសមាជិកអប្បបរមាដែលបានកំណត់ដោយមាត្រា ១០ នៃច្បាប់ស្តីពីសហជីព។ ដោយស្នើកាត់បន្ថយចំនួនសមាជិកអប្បបរមាសម្រាប់ការបង្កើតសហជីពមូលដ្ឋានទៅចំនួន ៧ សហជីព ។ ក្រុមសហជីពក៏បានស្នើសុំកាត់បន្ថយចំនួនសហជីពមូលដ្ឋានមានបញ្ជិកាសម្រាប់ការបង្កើតសហព័ន្ធសហជីពទៅចំនួន ៥ សហជីព ហើយចំនួនសហព័ន្ធសហជីពមានបញ្ជិកា សម្រាប់ការបង្កើតសហភាពការងារទៅចំនួន ៣ សហព័ន្ធ ។

៥.៤ លើសពីនេះទៀត ក្រុមសហជីពបានស្នើសុំឱ្យមានបទប្បញ្ញត្តិពិសេសសម្រាប់កម្មករដែលធ្វើការតាមផ្ទះ។ ដោយស្នើរួមបញ្ចូលសេរីភាពសម្រាប់កម្មករធ្វើការតាមផ្ទះទាំងនេះក្នុងការចូលជាសមាជិកសហជីព ឬសហព័ន្ធសហជីព ឬសមាគមកម្មករណាមួយតាមការជ្រើសរើសរបស់ខ្លួន ។ ក្រុមសហជីពក៏បានស្នើសុំឱ្យកម្មករដែលធ្វើការតាមផ្ទះមានសិទ្ធិក្នុងការបង្កើតសហជីពតាមផ្ទះសម្បែងជាច្រើនទៀត ។

៥.៥ មាត្រា ២ នៃអនុសញ្ញា C87 ចែងថា "ដោយគ្មានការប្រកាន់អ្វីទាំងអស់ កម្មករនិយោជិតនិងនិយោជកមានសិទ្ធិក្នុងការ … ចូលជាសមាជិកអង្គការតាមការជ្រើសរើសរបស់ខ្លួនដោយមិនត្រូវការការអនុញ្ញាត

ជាមុន ។" នៅក្នុងឆ្នាំ ២០១៧ ខាង CEACR បានលើកឡើងពីបញ្ហាប្រឈមរបស់កម្មករដែលធ្វើការតាមផ្ទះនិងកម្មករផ្សេងទៀតដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងការបង្កើត ឬការចូលជាសមាជិកសហជីពដោយលក្ខខណ្ឌតម្រូវការសមាជិកអប្បបរមាដែលកំណត់ដោយមាត្រា ១០ នៃច្បាប់ស្តីពីសហជីព ។[20] ខាង CEACR ក៏បានអំពាវនាវដល់រដ្ឋាភិបាលឱ្យ "លើកកម្ពស់ការប្រើប្រាស់សិទ្ធិពេញលេញនិងមានប្រសិទ្ធិភាពសម្រាប់កម្មករដែលធ្វើការតាមផ្ទះនិងកម្មករដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ដោយបើកសិទ្ធិជូនពួកគាត់ក្នុងការបង្កើតសហជីពថ្នាក់វិស័យ ឬតាមមុខរបរ ។[21] ការស្នើរបស់ខាង CEACR ស្រដៀងគ្នានឹងវិធីសាស្ត្រនិងរបៀបចងក្រងសមាជិកដែលប្រើប្រាស់ដោយសមាគមកម្មករដែលមិនគ្របដណ្តប់ដោយច្បាប់ស្តីពីសហជីព។ឧទាហរណ៍ សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) កំពុងចងក្រងកម្មករដែលធ្វើការតាមផ្ទះនិងកម្មករផ្សេងទៀតដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដូចជាអ្នករត់តុកតុកឬកង់បី អ្នកលក់តាមទីផ្សារ និងអ្នកលក់តាមផ្លូវដោយឱ្យពួកគាត់ចូលជាសមាជិកសមាគមដោយផ្ទាល់។ ដូចគ្នានឹងនេះដែរ សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA) និងសមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA) ក៏ចងក្រងគ្រូបង្រៀននិងមន្ត្រីរាជការដោយឱ្យពួកគាត់ចូលជាសមាជិកសមាគមដោយផ្ទាល់ដែរ ។

៥.៦ ទោះបីជាការស្នើសុំរបស់ក្រុមសហជីពនឹងលើកកម្ពស់សេរីភាពក្នុងការបង្កើតសមាគមដោយកាត់បន្ថយចំនួនសមាជិកអប្បបរមា ហើយក៏ដោះស្រាយបញ្ហាប្រឈមរបស់កម្មករដែលធ្វើការតាមផ្ទះក្នុងការបង្កើតសហជីព ការស្នើសុំនេះមិនគ្រប់គ្រាន់ក្នុងការលើកកម្ពស់សេរីភាពក្នុងការបង្កើតសមាគមសម្រាប់កម្មករទាំងអស់ដែរ ។ ឧទាហរណ៍ កម្មករដែលធ្វើការក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានកម្មករនិយោជិតតិចជាង ១០ នាក់ (ឬ ៧ នាក់តាមការស្នើសុំរបស់ក្រុមសហជីព) នៅតែមិនមានលទ្ធភាពក្នុងការបង្កើតសហជីពទេ ដោយសារមិនមានចំនួនសមាជិកអប្បបរមាដែលកំណត់ដោយច្បាប់ ។ លើសពីនេះទៀត ការស្នើសុំរបស់ក្រុមសហជីពមិនគិតពីសិទ្ធិពិសេសសម្រាប់កម្មករផ្សេងទៀតដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬកម្មករដែលធ្វើការក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានកម្មករនិយោជិតតិចជាងចំនួនដែលតម្រូវដើម្បីបង្កើតសហជីព (ប៉ុន្តែសិទ្ធិពិសេសដែលត្រូវបានស្នើសុំសម្រាប់កម្មករដែលធ្វើការក្នុងផ្ទះក៏អាចផ្តល់ជូនកម្មករទាំងនោះផងដែរបាន) ។

*អនុសាសន៍ ៖*

៥.៧ ត្រូវធ្វើវិសោធនកម្មលើមាត្រា ១០ ដើម្បីផ្តល់សិទ្ធិពិសេសជូនកម្មករធ្វើការតាមផ្ទះនិងកម្មករដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដើម្បីឱ្យពួកគាត់បង្កើតសហជីពដោយមានអ្នកស្ថាបនិកតិចជាងចំនួនអប្បបរមាដែលកំណត់ដោយច្បាប់ ឬឱ្យពួកគាត់ចូលជាសមាជិកសហជីពតាមវិស័យទូលំទូលាយដូចអនុសាសន៍ដោយ CEACR ។ ថែមពីនេះទៀតត្រូវមានបទប្បញ្ញត្តិដែលផ្តល់សិទ្ធិបង្កើតសហជីពជូនកម្មករដែលធ្វើការក្នុងសហគ្រាសឬគ្រឹះស្ថានដែលមានកម្មករតិចជាងចំនួនចំនួនអប្បបរមាកំណត់ដោយច្បាប់សម្រាប់ការបង្កើតសហជីពមូលដ្ឋានមួយ ។

# ៦. មាត្រា១២ លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំចុះបញ្ជី

៦.១ មាត្រា ១២ នៃច្បាប់ស្តីពីសហជីពមិនត្រូវបានធ្វើវិសោធនកម្មទេ ។

៦.២ យោងតាមមាត្រា ១២ នៃច្បាប់ស្តីពីសហជីព សហជីពត្រូវដាក់ឯកសារមួយចំនួនដើម្បីទទួលបានការចុះបញ្ជីពីក្រសួងការងារនិងបណ្តុះបណ្តាលវិជាជីវៈ។ ឯកសារទាំងនោះរួមបញ្ចូលលក្ខន្តិកៈសហជីព បទប្បញ្ញត្តិរដ្ឋបាល បញ្ជីឈ្មោះអ្នកដឹកនាំ កិច្ចសន្យាធានាថានឹងផ្តល់រាល់ព័ត៌មានគណនីធនាគាររបស់ខ្លួនក្នុងរយៈពេល ៤៥ ថ្ងៃគិតពីថ្ងៃទទួលបានការចុះបញ្ជី និងបញ្ជីឈ្មោះសមាជិកស្ថាបនិក ។ មាត្រា ១៥ នៃច្បាប់ស្តីពីសហជីពចែងថា នីតិវិធីនិងបែបបទនៃការដាក់ពាក្យសុំចុះបញ្ជីសហជីពឬសមាគមនិយោជកត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ទទួលបន្ទុកវិស័យការងារ ។ បច្ចុប្បន្ន នីតិវិធីនិងបែបបទនេះត្រូវបានកំណត់ដោយប្រកាសលេខ២៤៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីសហជីពនិងសមាគមនិយោជក ។ យោងតាមប្រកាសនេះ ថ្នាក់ដឹកនាំក៏ត្រូវដាក់រូបថតផ្ទាល់ខ្លួន រួមទាំងប្រវត្តិរូបសង្ខេបដោយមានព័ត៌មានផ្ទាល់ខ្លួនហើយទាក់ទងនិងគ្រួសារដូចជាឈ្មោះ អាសយដ្ឋានមុខរបរ និងព័ត៌មានទាក់ទងរបស់ប្តីប្រពន្ធនិងឳពុកម្តាយ ។[22] លើសពីនេះទៀត ប្រកាសនេះតម្រូវឱ្យថ្នាក់ដឹកនាំសហជីពផ្តល់សេចក្តីប្រកាសផ្ទាល់ខ្លួនដែលបញ្ជាក់ថាគាត់ចេះអានចេះសរសេរអក្សរខ្មែរ និងមិនធ្លាប់ទទួលការផ្តន្ទាទោសពីពទមជ្ឈឹម ឬបទឧក្រិដ្ឋទេ ។[23]

៦.៣ មាត្រា ២ នៃអនុសញ្ញា C87 ចែងថាកម្មករមានសិទ្ធិក្នុងការបង្កើតសហជីព "ដោយមិនត្រូវការការអនុញ្ញាតជាមុន" ។ នៅក្នុងឆ្នាំ ២០១៧ បេសកកម្មទំនាក់ទំនងផ្ទាល់របស់ខាង CEACR បានលើកឡើងការព្រួយបារម្ភពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវការដាក់ព័ត៌មានដែល "ប្រហែលជាអាចបង្អាក់ឬធ្វើឱ្យនីតិវិធីសុំចុះបញ្ជីការមានភាពស្មុគស្មាញ" ដូចជាព័ត៌មានផ្ទាល់ខ្លួនលម្អិតរបស់ថ្នាក់ដឹកនាំនិងគ្រួសាររបស់ពួកគាត់ ឬបញ្ជីឈ្មោះអ្នកដែលចូលរួមក្នុងការបោះឆ្នោតបង្កើតសហជីព ។[24] ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឆ្លើយតបទៅនឹងការព្រួយបារម្ភនេះដោយដកចេញលក្ខខណ្ឌតម្រូវការឱ្យថ្នាក់ដឹកនាំផ្តល់ព័ត៌មានអំពីសមាជិកគ្រួសារតាមរយៈសេចក្តីណែនាំមួយដែលបានចេញនៅខែធ្នូ ឆ្នាំ ២០១៨[25] ប៉ុន្តែមិនទាន់មានវិសោធនកម្មជាផ្លូវការទៅនឹងបទប្បញ្ញត្តិនៃប្រកាសលេខ២៤៩នៅឡើយទេ ។ ក្នុងអំឡុងពេល នោះ អ្នកតំណាងរបស់រាជរដ្ឋាភិបាលក៏បានលើកឡើងថា បែបបទចុះបញ្ជីការដែលភ្ជាប់ទៅនឹងប្រកាសលេខ២៤៩មិនមានលក្ខខណ្ឌៈចាំបាច់ក្នុងការប្រើប្រាស់ទេ[26] ប៉ុន្តែ ការលើកឡើងនេះហាក់ដូចជាផ្ទុយទៅនឹងពាក្យដែលត្រូវបានប្រើប្រាស់ ទាំងច្បាប់ស្តីពីសហជីព[27] និងប្រកាសលេខ២៤៩[28] ។

៦.៤ ក្រោយពីបញ្ចប់បេសកកម្មនេះ ខាង CEACR បានស្នើសុំឱ្យរាជរដ្ឋាភិបាលចាត់វិធានការចាំបាច់ដើម្បី "ធានាថានីតិវិធីសុំចុះបញ្ជីត្រូវបានធ្វើឡើងដោយមានភាពសាមញ្ញ ភាពយុត្តិធម៌ និងតម្លាភាព ដែលមិនមានការសម្រេចចិត្តឬការអនុញ្ញាតតជាមុនណាមួយ" ហើយនិងនិងតាមរយៈការពិគ្រោះយោបល់ទូលំ

ទូលាយជាមួយកម្មករ ដើម្បី"ដកចេញលក្ខខណ្ឌតម្រូវការដែលទោះបីជាសំខាន់សម្រាប់ការចុះបញ្ជីដែលអាចបង្អាក់ឬធ្វើឱ្យនីតិវិធីសុំចុះបញ្ជីមានភាពស្មុគស្មាញ និងធ្វើវិសោធនកម្មនៅពេលចាំបាច់និងវាយតម្លៃការអនុវត្តនៃ [ច្បាប់ស្តីពីសហជីព] និងបទប្បញ្ញត្តិនៃច្បាប់លើដំណើរការចុះបញ្ជី ។"[29]

៦.៥ ស្ថិតិពីក្រុមឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជាបង្ហាញថា នីតិវិធីសុំចុះបញ្ជីមានភាពងាយស្រួលជាងមុនចំពោះសហជីពតាំងពីពេលមានការស្នើសុំពីខាង CEACR ។ នៅក្នុងរយៈពេលឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ មានតែ ៤៥,៨ ភាគរយនៃសហជីពដែលត្រូវបានតាមដានដែលបានទទួលការចុះបញ្ជីពីក្រសួង[30] ដោយមាន ៨១,០៨ ភាគរយនៃសហជីពដែលលើកឡើងថាគេមានការលំបាកក្នុងការបំពេញពាក្យសុំចុះបញ្ជី ។[31] នៅក្នុង ឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩ តួលេខនៃសហជីពដែលត្រូវបានទទួលបានការចុះបញ្ជីបានកើនឡើងដល់ ៨៣ ភាគរយ ដោយមានសហជីពភាគច្រើនលើកឡើងថាគេមានភាពងាយស្រួលក្នុងការបំពេញពាក្យសុំចុះបញ្ជី ។[32] ប៉ុន្តែ នៅតែមានតម្រូវការមួយចំនួនដែលខាង CEACR បានលើកឡើង ដូចជាបញ្ជីឈ្មោះអ្នកដែលចូលរួមក្នុងការបោះឆ្នោតបង្កើតសហជីពនៅបន្តមាននៅឡើយទេ ។[33]

៦.៦ នីតិវិធីសុំចុះបញ្ជីនិងលក្ខខណ្ឌតម្រូវការនៃមាត្រា ១២ នៃច្បាប់ស្តីពីសហជីព និងបទប្បញ្ញត្តិនៃប្រកាសលេខ ២៤៩ នៅតែតម្រូវឱ្យសហជីពទទួលបាន "ការអនុញ្ញាតជាមុន" ដែលមិនដូចនឹងមាត្រា ២ នៃអនុសញ្ញា C87ឡើយ ។ យោងតាមច្បាប់ស្តីពីសហជីព ពាក្យសុំចុះបញ្ជីត្រូវដាក់ទៅនិងអនុម័តដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ លើសពីនេះទៀត មាត្រា ១៤ នៃច្បាប់ស្តីពីសហជីពចាត់ទុកសហជីពដែលគ្មានការចុះបញ្ជីថាខុសច្បាប់ និងយោងតាមមាត្រា ៨០ នៃច្បាប់ស្តីពីសហជីព ច្បាប់ដាក់ទោសពិន័យលើសហជីពនោះក្នុងករណីសហជីពមានប្រតិបត្តិការដោយគ្មានការចុះបញ្ជីដែលអនុញ្ញាតតពីក្រសួង ។ ដូច្នេះ ដើម្បីអោយសហជីពដំណើរការស្របតាមច្បាប់ សហជីពត្រូវតែតម្រូវអោយទទួលបានការអនុញ្ញាតជាមុនពីអាជ្ញាធរដោយតទទួលបានការចុះបញ្ជីដែលអនុញ្ញាតដែរ ។ ទោះបីជាការដាក់ពាក្យសុំចុះបញ្ជីជូនរដ្ឋមិនមានការអនុញ្ញាតជាមុន ក្នុងករណីដែលនីតិវិធីសុំចុះបញ្ជីសាមញ្ញ[34] នីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីសហជីព និងប្រកាសលេខ ២៤៩ គឺលើសកម្រិតនៃគោលការណ៍នេះហើយ ។ ឧទាហរណ៍ ទោះបីជាមានការកើនឡើងក្នុងចំនួនសហជីពដែលបានទទួលការចុះបញ្ជីនៅក្នុងរយៈពេលឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩ នៅតែមាន ៥៤ ភាគរយនៃសហជីពដែលត្រូវបានព្យាយាមដាក់ពាក្យសុំចុះបញ្ជីជាច្រើនដងមុនទទួលបានការចុះបញ្ជី ។[35]

*អនុសាសន៍ ៖*

៦.៧ ត្រូវធ្វើវិសោធនកម្មលើមាត្រា ១២ នៃច្បាប់ស្តីពីសហជីព និងប្រកាសលេខ ២៤៩/១៦ ដើម្បីធានាថាការស្នើសុំចុះបញ្ជីមិនតម្រូវឱ្យសហជីព ឬសមាគមនិយោជកទទួលការអនុញ្ញាតជាមុនពីអាជ្ញាធរ ពោល

គឺអោយមានភាពសមប្រកបត្រឹមត្រូវ។ ដូច្នេះ ត្រូវដកចេញលក្ខខណ្ឌតម្រូវការមួយចំនួនដូចជា អាសយដ្ឋានសម្រាប់ថែរក្សាទុកនូវសៀវភៅហិរញ្ញវត្ថុ និងកំណត់ត្រាហិរញ្ញវត្ថុ[36] កិច្ចសន្យាធានាថានឹងផ្តល់រាល់ព័ត៌មានគណនីធនាគាររបស់ខ្លួនក្នុងរយៈពេល ៤៥ ថ្ងៃគិតពីថ្ងៃទទួលបានការចុះបញ្ជី[37] កំណត់ហេតុច្បាប់ដើមនៃការបោះឆ្នោតបង្កើតអង្គការវិជ្ជាជីវៈ[38] និងបញ្ជីរាយនាមកម្មករនិយោជិតទាំងអស់ដែលជាសមាជិកនៅក្នុងសហគ្រាស ឬគ្រឹះស្ថាន ។[39] លើសពីនេះទៀត ត្រូវធ្វើវិសោធនកម្មលើប្រកាសលេខ ២៤៩/១៦ ដើម្បីដកចេញលក្ខខណ្ឌតម្រូវការពាក់ព័ន្ធការដាក់រូបថតនិងព័ត៌មានផ្ទាល់ខ្លួនរបស់ថ្នាក់ដឹកនាំសហជីព ហើយនិងសេចក្តីប្រកាសថាចេះអានចេះសរសេរអក្សរខ្មែរនិងមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈឹមឬបទឧក្រិដ្ឋ[40] ក៏ដូចជាធ្វើឱ្យមានលក្ខណៈផ្លូវការនូវការដកចេញលក្ខខណ្ឌតម្រូវការដាក់ព័ត៌មានអំពីគ្រួសាររបស់ថ្នាក់ដឹកនាំ ។

## ៧. មាត្រា ១៣ – លក្ខខណ្ឌតម្រូវសម្រាប់លក្ខន្តិកៈ

**៧.១** មាត្រា ១៣ មិនត្រូវបានធ្វើវិសោធនកម្មកន្លងមកថ្មីៗនេះទេ ។

**៧.២** មាត្រា ១៣ កំណត់លក្ខខណ្ឌតម្រូវការមួយចំនួនសម្រាប់លក្ខន្តិកៈសហជីពនិងសមាគមនិយោជក ។ យោងតាមមាត្រានេះ លក្ខន្តិកៈត្រូវមានប្រការពាក់ព័ន្ធការកំណត់ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុជាធម្មតា និងការបោះពុម្ពផ្សាយជាប្រចាំនូវរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់សហជីពឬសមាគមនិយោជក រួមទាំងលក្ខណសម្បត្តិសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលយ៉ាងហោចណាស់ឱ្យស្របតាមមាត្រា ២០ និង ២១ នៃច្បាប់ស្តីពីសហជីព ។ លើសពីនេះទៀត លក្ខន្តិកៈត្រូវកំណត់ចំនួនកូរ៉ុមប្រជុំចំនួនភាគច្រើនដាច់ខាត (ចំនួនយ៉ាងតិច ៥០%+១) នៃសមាជិកសហជីពសរុបសម្រាប់រាល់កិច្ចប្រជុំសម្រេចធ្វើកូដកម្ម រួមទាំងតម្រូវឱ្យមានការបោះឆ្នោតជាសម្ងាត់ដោយសំឡេងយ៉ាងតិច ៥០%+១ នៃសមាជិកដែលចូលរួមកិច្ចប្រជុំសម្រេចធ្វើកូដកម្ម ។ ទន្ទឹមនឹងនេះដែរ មាត្រា១៣លើកឡើងថា លក្ខន្តិកៈត្រូវកំណត់ចំនួនប្រាក់ភាគទានដែលសមាជិកម្នាក់ៗត្រូវតែបង់ និងបែបបទនៃការបង់ប្រាក់ភាគទានប្រចាំខែត្រូវកំណត់ដោយមហាសន្និបាតឬសន្និបាតរបស់សហជីព ។ យោងតាមមាត្រា ១២ នៃច្បាប់ស្តីពីសហជីព លក្ខន្តិកៈនេះក៏ត្រូវដាក់ទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីទទួលការចុះបញ្ជី ។ លើសពីនេះទៅទៀត សហជីពត្រូវប្រើប្រាស់គំរូលក្ខន្តិកៈដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងប្រកាសលេខ ២៤៩/១៦ ។[41]

**៧.៣** មាត្រា ៣ នៃអនុសញ្ញា C87 ចែងថា អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតនិងនិយោជក "មានសិទ្ធិក្នុងការបង្កើតលក្ខន្តិកៈនិងវិធានរបស់ខ្លួន" ហើយនិង "អាជ្ញាធរសាធារណៈត្រូវជៀសវាងពីការជ្រៀតជ្រែកណាមួយដែលរឹតត្បិតលើសិទ្ធិនេះ ឬរារាំងការប្រើប្រាស់សិទ្ធិនេះតាមច្បាប់ ។" ស្តង់ដារការងារអន្តរជាតិតម្រូវឱ្យច្បាប់ជាតិកំណត់តែលក្ខខណ្ឌតម្រូវការមូលដ្ឋានសមរម្យសម្រាប់

លក្ខន្តិកៈសហជីព ហើយបទប្បញ្ញត្តិដែលហួសពីតម្រូវការមូលដ្ឋាននេះគឺជា "ការជ្រៀតជ្រែកដែលផ្ទុយទៅនឹងសិទ្ធិរបស់អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតក្នុងការបង្កើតលក្ខន្តិកៈនិងវិធានរបស់ខ្លួនយោងតាមមាត្រា ៣ នៃ [អនុសញ្ញា C87] ។[42] ទាក់ទងនឹងតម្រូវការសម្រាប់លក្ខន្តិកៈដូចកំណត់ដោយច្បាប់ស្តីពីសហជីព ខាង CEACR បានថែងថាតម្រូវការ "ការកំណត់ពីចំនួនកូរ៉ុម ឬការរៀបចំបោះឆ្នោតសម្រាប់ការសម្រេចចិត្តហួសពីតម្រូវការមូលដ្ឋាន និងការកំណត់ពីរឿងទាំងនោះគួរតែជាការសម្រេចចិត្តរបស់សហជីពជាផ្ទាល់ ។"[43] ដូច្នេះ ខាង CEACR ក៏បានស្នើសុំឱ្យរាជរដ្ឋាភិបាល "ជួបពិភាក្សាជាមួយដៃគូសង្គមដើម្បីដកចេញតម្រូវការនេះដែលរឹតត្បិតលើសិទ្ធិបង្កើតលក្ខន្តិកៈនិងវិធានការរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកពីអាជ្ញាធរសាធារណៈ ។"[44]

៧.៤ ទោះយ៉ាងណាក៏ដោយ តម្រូវការផ្សេងៗដែលកំណត់ដោយមាត្រា ១៣ ក៏ហួសពី "តម្រូវការមូលដ្ឋាន" ដែលអនុញ្ញាតដោយស្តង់ដារអន្តរជាតិផងដែរ។ ទាំងនោះក៏មានដូចជាការកំណត់ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុជាធម្មតា និងការបោះឆ្នោតពុម្ពផ្សាយជាប្រចាំនូវរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុ ការកំណត់ចំនួនប្រាក់ភាគទានដែលសមាជិកម្នាក់ៗត្រូវតែបង់ ការកំណត់ថាបែបបទនៃការបង់ប្រាក់ភាគទានប្រចាំខែត្រូវកំណត់ដោយមហាសន្និបាត ឬសន្និបាតរបស់សហជីព និងលក្ខណសម្បត្តិសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលយ៉ាងហោចណាស់ឱ្យស្របតាមមាត្រា ២០ និង ២១ នៃច្បាប់ស្តីពីសហជីព ។ រឿងទាំងនេះគួរសម្រេចចិត្តដោយសហជីព ហើយការកំណត់រឿងទាំងនេះដោយច្បាប់គឺជាការជ្រៀតជ្រែកដែលផ្ទុយទៅនឹងសិទ្ធិរបស់អង្គការវិជ្ជាជីវៈរបស់កម្មករក្នុងការបង្កើតលក្ខន្តិកៈនិងវិធានរបស់ខ្លួនតាមមាត្រា ៣ នៃអនុសញ្ញា C87 ។ លើសពីនេះទៀត ការតម្រូវការឱ្យសហជីពប្រើប្រាស់គំរូលក្ខន្តិកៈដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងប្រកាសលេខ ២៤៩/១៦ ក៏ត្រូវបានផ្ទុយទៅនឹងស្តង់ដារការងារអន្តរជាតិផងដែរ ។[45] ដូចបានលើកឡើងក្នុងកថាខណ្ឌលេខ ៦.៣ ខាងលើ រាជរដ្ឋាភិបាលបានលើកឡើងទៅ CEACR ថាបែបបទនេះមិនជាប់ចាំបាច់សម្រាប់ការប្រើប្រាស់ទេ ប៉ុន្តែពាក្យពេចន៍នៃមាត្រា ១៥ នៃច្បាប់ស្តីពីសហជីព និងប្រកាសលេខ ២៤៩/១៦ មិនទាន់ឆ្លុះបញ្ចាំងទៅនឹងការលើកឡើងនេះបានត្រឹមត្រូវទេ ។

*អនុសាសន៍ ៖*

៧.៥ ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៣ ដើម្បីដកចេញលក្ខខណ្ឌតម្រូវការដូចខាងក្រោម ៖

- ការកំណត់ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុជាធម្មតា និងការបោះពុម្ពផ្សាយជាប្រចាំនូវរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់សហជីព ឬសមាគមនិយោជក ;
- ការកំណត់ចំនួនកូរ៉ុមប្រជុំចំនួនភាគច្រើនដាច់ខាត (ចំនួនយ៉ាងតិច ៥០%+១) នៃសមាជិកសហជីពសរុបសម្រាប់រាល់កិច្ចប្រជុំសម្រេចធ្វើកូដកម្ម កែប្រែលក្ខន្តិកៈ និងមហាសន្និបាតរបស់សហជីព ;
- លក្ខខណ្ឌតម្រូវឱ្យមានការបោះឆ្នោតជាសម្ងាត់ដោយសំឡេងយ៉ាងតិច ៥០%+១ នៃសមាជិកដែលចូលរួមកិច្ចប្រជុំសម្រេចធ្វើកូដកម្ម ;
- ការកំណត់ចំនួនប្រាក់ភាគទានដែលសមាជិកម្នាក់ៗត្រូវតែបង់និងបែបបទនៃការបង់ប្រាក់ភាគទានប្រចាំខែត្រូវកំណត់ដោយមហាសន្និបាត ឬសន្និបាតរបស់សហជីព ;
- លក្ខណសម្បត្តិសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលយ៉ាងហោចណាស់ឱ្យស្របតាមមាត្រា ២០ និង មាត្រា ២១ នៃច្បាប់ស្តីពីសហជីព ។

៧.៦ ត្រូវដកចេញប្រការ ៣ នៃប្រកាសលេខ ២៤៩/១៦ នូវការតម្រូវការស្រដៀងគ្នានឹងការតម្រូវការខាងលើនេះ ។ លើសពីនេះទៀត ត្រូវធ្វើវិសោធនកម្មលើប្រកាសលេខ ២៤៩/១៦ ដើម្បីឱ្យច្បាស់លាស់ថាលក្ខន្តិកៈគំរូនៅក្នុងឧបសម្ព័ន្ធទី២នៃប្រកាសមិនមែនទម្រង់ជាចាំបាច់សម្រាប់សហជីព និងឬសមាគមនិយោជកសម្រាប់ប្រើប្រាស់ទេ ។

## ៨. មាត្រា ១៤ – អានុភាពនៃការចុះបញ្ជី

៨.១ មាត្រា ១៤ មិនត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះទេ ។ យោងតាមលិខិតដូចបានពិភាក្សានៅក្នុងបុព្វកថា និងកថាខណ្ឌលេខ ៥.១ ខាងលើដែលត្រូវបានផ្ញើជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាក់ទងនឹងការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសហជីព ក្រុមសហជីពបានស្នើសុំឱ្យមានវិសោធនកម្មលើមាត្រា ១៤ ប៉ុន្តែហាក់ដូចជាក្រសួងមិនបានទទួលយកការស្នើសុំនេះទេ ។

៨.២ មាត្រា ១៤ ចែងថាមានតែសហជីពឬសមាគមនិយោជកដែលបានទទួលការចុះបញ្ជីរួចហើយដែលមានបុគ្គលភាពគតិយុត្តនិងភាពស្របច្បាប់ ។ លើសពីនេះទៀត យោងតាមមាត្រានេះ សហជីពឬសមាគមនិយោជកណាមួយដែលមិនបានចុះបញ្ជី ដែលត្រូវបានពន្យារពេលចុះបញ្ជី ឬដែលត្រូវបានលុបបញ្ជិកា ហើយបានធ្វើសកម្មភាពសហជីព ឬសកម្មភាពជាសមាគមនិយោជកត្រូវបានចាត់ទុកថាខុសច្បាប់ ។ ការពិន័យសម្រាប់សហជីពដែលមានប្រតិបត្តិការដោយគ្មានការចុះបញ្ជីត្រូវបានកំណត់ដោយមាត្រា ៨០ ដោយជាដំបូងព្រមានជាលាយលក្ខណ៍អក្សរហើយពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៥.០០០.០០០ រៀល (ប្រមាណ ១២៣០ ដុល្លារអាមេរិច) ក្នុងករណីមិនគោរពតាមការព្រមាន ។

៨.៣ ទន្ទឹមនឹងនេះក្រុមសហជីពបានស្នើសុំវិសោធនកម្មលើមាត្រា ១៤ ។ យោងតាមការស្នើសុំរបស់ក្រុមសហជីព សមាជិកស្ថាបនិកមានសិទ្ធិក្នុងការធ្វើសកម្មភាពសហជីព (ឧ. ដោះស្រាយវិវាទការងាររួមដាក់ពាក្យបណ្តឹង និងការការពារពិសេសពីការបញ្ឈប់) ចាប់ពីថ្ងៃជូនដំណឹងដល់និយោជកអំពីការបោះឆ្នោតបង្កើតសហជីព ។ លើសពីនេះទៀត សហជីពក៏បានស្នើសុំការលុបចោលនូវកថាខណ្ឌទីបីនៃមាត្រា ១៤ ដែលហាមឃាត់សហជីពពីការប្រកបរបរជំនួញវៀរលែងតែសកម្មភាពស្របច្បាប់ដែលមានចែងក្នុងចំណុច "ធ" នៃមាត្រា ៥៩ នៃច្បាប់ស្តីពីសហជីព ។

៨.៤ មាត្រា ២ នៃអនុសញ្ញា C87 ចែងថាកម្មករនិយោជិតមានសិទ្ធិក្នុងការបង្កើតសហជីព "ដោយមិនត្រូវការការអនុញ្ញាតជាមុន" ។ មាត្រា ១៤ តម្រូវឱ្យសហជីពទទួលបានការអនុញ្ញាតជាមុនពីអាជ្ញាធរដោយមាត្រានេះមិនផ្តល់បុគ្គលភាពគតិយុត្តនិងភាពស្របច្បាប់ជូនសហជីពដែលពាក្យសុំចុះបញ្ជីរបស់គេមិនត្រូវបានយល់ព្រមដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយដាក់ទណ្ឌកម្មលើសហជីពនោះក្នុងករណីធ្វើសកម្មភាព ។ ទោះបីជានីតិវិធីសុំចុះបញ្ជីមិនផ្ទុយទៅនឹងស្តង់ដារការងារអន្តរជាតិនីតិវិធីទាំងនេះគួរសាមញ្ញ ហើយមិនគួរមានការសម្រេចចិត្តឬការអនុញ្ញាតណាមួយជាមុនឡើយ ។[46] ការមិនផ្តល់បុគ្គលភាពគតិយុត្តជូនសហជីពដែលពាក្យសុំចុះបញ្ជីរបស់គេមិនត្រូវបានយល់ព្រមដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមទាំងការដាក់ទណ្ឌកម្មចំពោះសហជីពដែលប្រតិបត្តិការដោយគ្មានការយល់ព្រមពីការចុះបញ្ជីនេះ គឺជាតម្រូវការច្បាស់លាស់ណាស់ដែលត្រូវឱ្យទទួលបានការអនុញ្ញាតជាមុនពីអាជ្ញាធរដែលផ្ទុយទៅនឹងមាត្រា ២ នៃអនុសញ្ញា C87 ។

៨.៥ ក្នុងន័យនេះ ការស្នើសុំរបស់ក្រុមសហជីពសម្រាប់ការធ្វើវិសោធនកម្មលើមាត្រា ១៤ ហាក់ដូចជាស្របតាមស្តង់ដារការងារអន្តរជាតិខាងលើនេះដោយនៅតែតម្រូវឱ្យសហជីពសុំចុះបញ្ជីតែផ្តល់បុគ្គលភាពគតិយុត្ត ភាពស្របច្បាប់ និងសិទ្ធិក្នុងការធ្វើសកម្មភាពចាប់ពីថ្ងៃជូនដំណឹងដល់និយោជ ។ វិធីសាស្ត្រនេះស្របតាមស្តង់ដារការងារអន្តរជាតិដោយធានាថាការចុះបញ្ជីសហជីពមានទម្រង់ស្របច្បាប់ត្រឹមត្រូវនិងមិនសុំការអនុញ្ញាតជាមុនដូចបានកំណត់ដោយបទប្បញ្ញត្តិបច្ចុប្បន្ន ។

*អនុសាសន៍*

៨.៦ ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៤ យោងតាមការស្នើសុំរបស់សហជីពដោយផ្តល់បុគ្គលភាពគតិយុត្តនិងសិទ្ធិក្នុងការធ្វើសកម្មភាពនិងប្រតិបត្តិការជាទូទៅជូនសហជីពចាប់ពីថ្ងៃជូនដំណឹងដល់និយោជកអំពីការបោះឆ្នោតបង្កើតសហជីព ។

# ៩. មាត្រា ១៥ – ចំណាត់ការនៅលើការដាក់ពាក្យសុំចុះបញ្ជី

៩.១ មាត្រា ១៥ មិនត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះទេ ។

៩.២ មាត្រា ១៥ ចែងថានីតិវិធីនិងបែបបទនៃការដាក់ពាក្យសុំចុះបញ្ជីសហជីព ឬសមាគមនិយោជកត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ ដែលបច្ចុប្បន្ននេះត្រូវបានកំណត់ដោយប្រកាសលេខ ២៤៩/១៦ ។ ដូចបានពិភាក្សានៅក្នុងកថាខណ្ឌលេខ ៦.៣ ខាងលើ រាជរដ្ឋាភិបាលបានលើកឡើងទៅខាង CEACR ថា គំរូនានាដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងប្រកាសលេខ ២៤៩/១៦ មិនចាំបាច់ ក្នុងការប្រើប្រាស់ទេ តែជាគំរូត្រូវបានតែលើកឧទាហរណ៍សម្រាប់ការប្រើប្រាស់ ។ ទោះយ៉ាងណាក៏ដោយ ពាក្យពេចន៍ដែលបានប្រើប្រាស់ក្នុងទាំងមាត្រា ១៥ នៃច្បាប់ស្តីពីសហជីព និងបទប្បញ្ញត្តិនៃប្រកាសលេខ ២៤៩/១៦ ផ្តល់ជាគំនិតថាគំរូដែលត្រូវបានភ្ជាប់ចាំបាច់ក្នុងការប្រើប្រាស់ ។

*អនុសាសន៍ ៖*

៩.៣ ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៥ និង/ឬ ប្រកាសលេខ ២៤៩/១៦ ដើម្បីឱ្យច្បាស់លាស់ថាគំរូដែលភ្ជាប់ទៅប្រកាសជាឧបសម្ព័ន្ធមិនមែនគំរូចាំបាច់សម្រាប់សហជីពនិងសមាគមនិយោជក ។

## ១០. មាត្រា ១៦ – ការពន្យារពេលការចុះបញ្ជី

១០.១ មាត្រា ១៦ មិនត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះទេ ។

១០.២ មាត្រា ១៦ ផ្តល់ឱ្យមានការពន្យារពេលនូវរយៈពេល ៣០ ថ្ងៃសម្រាប់ការសម្រេចចិត្តលើការចុះបញ្ជីសហជីពឬសមាគមនិយោជកដែលត្រូវបានកំណត់ដោយមាត្រា ១២ ក្នុងករណីមួយចំនួន ។ យោងតាមកថាខណ្ឌ "ឃ" នៃមាត្រា ១៦ រយៈពេល ៣០ ថ្ងៃនេះអាចពន្យារពេលបានក្នុងករណីលក្ខន្តិកៈរបស់សហជីពឬសមាគមនិយោជកមិនបានបំពេញលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីសហជីព ឬបទបញ្ជាទាំងឡាយសម្រាប់អនុវត្តច្បាប់ស្តីពីសហជីព ។ លើសពីនេះទៀត យោងតាមកថាខណ្ឌ "ង" នៃមាត្រា ១៦ រយៈពេល ៣០ ថ្ងៃនេះក៏អាចពន្យារពេលក្នុងករណីអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលសហជីពឬសមាគមនិយោជកមិនបានបំពេញគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និង ២១ នៃច្បាប់ស្តីពីសហជីព ។

១០.៣ មាត្រា ៣ នៃអនុសញ្ញា C87 ចែងថាអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតឬនិយោជកមានសិទ្ធិក្នុងការបង្កើតលក្ខន្តិកៈនិងវិធានរបស់ខ្លួន និងហាមឃាត់អាជ្ញាធរពី "ការជ្រៀតជ្រែកណាមួយដែលអាចដាក់កម្រិតឬរារាំងការប្រើប្រាស់សិទ្ធិនេះស្របតាមច្បាប់ ។" នៅក្នុងករណីមុនៗ ខាង CFA បានចែងថាដើម្បីឱ្យច្បាប់ជាតិស្របតាមស្តង់ដារការងារអន្តរជាតិ ច្បាប់ជាតិស្តីអំពីលក្ខន្តិកៈសហជីពគួរកំណត់តែតម្រូវការមូលដ្ឋាន ហើយមិនត្រូវការការអនុញ្ញាតជាមុនតាមការសម្រេចចិត្តរបស់អាជ្ញាធរសាធារណៈទេ ។[47] ក្នុងន័យនេះ កថាខណ្ឌ "ឃ" នៃមាត្រា ១៦ ផ្ទុយទៅនឹងស្តង់ដារការងារអន្តរជាតិ ដោយកថា

ខណ្ឌនេះផ្តល់សិទ្ធិជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការពន្យារពេលផ្តល់ការចុះបញ្ជីជូនសហជីពដែលមានផលប៉ះពាល់ក្នុងការតម្រូវឱ្យលក្ខន្តិកៈសហជីពទទួលបានការយល់ព្រមពីក្រសួងជាមុន ។

១០.៤ មាត្រា ៣ នៃអនុសញ្ញា C87 ក៏ចែងថាអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតឬនិយោជកមានសិទ្ធិក្នុងការ "ជ្រើសរើសបោះឆ្នោតអ្នកតំណាងរបស់ខ្លួនដោយមានសេរីភាពពេញលេញ ។" កន្លងមកខាង CFA បានរកឃើញថាបទប្បញ្ញត្តិដែលកំណត់ពីលក្ខខណ្ឌតម្រូវសម្រាប់អ្នកដឹកនាំផ្អែកលើអាយុ (ដូចមានចែងក្នុងមាត្រា ២០ និង ២១ នៃច្បាប់ស្តីពីសហជីព ហើយកន្លងមកបានចែងក្នុងមាត្រា ២៨៦ នៃច្បាប់ស្តីពីការងារ(១៩៩៧) បានផ្ទុយទៅនឹងស្តង់ដារការងារអន្តរជាតិ ។[48]

*អនុសាសន៍ ៖*

១០.៦ ត្រូវដកចេញកថាខណ្ឌ ឃ និង ង ។

# ១១. មាត្រា ១៧ ថ្មី – ការរក្សាបញ្ជិកា និងមាត្រា ១៨ – ការជូនដំណឹងស្តីពីការកែតម្រូវ

១១.១ យោងតាមមាត្រា ១៧ ថ្មី ដើម្បីរក្សាបញ្ជិការបស់ខ្លួន សហជីពនិងសមាគមនិយោជកធ្វើរបាយការណ៍សកម្មភាពនិងរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយ "ស្ថាប័នសវនកម្មឯករាជដែលបានចុះបញ្ជីស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា" ក្នុងករណីមានការស្នើសុំពីសមាជិកចំនួនតិច (១០ ភាគរយចំពោះសហជីពមូលដ្ឋាននិងសមាគមនិយោជក និង ៥ ភាគរយចំពោះសហព័ន្ធសហជីព សហភាពសហជីព និងសហព័ន្ធនិយោជក) ឬម្ចាស់ជំនួយណាមួយ ។ ក្នុងករណីដែលសហជីពឬសមាគមនិយោជកមិនបំពេញតាមតម្រូវការនៃមាត្រា ១៧ សហជីព ឬសមាគមនិយោជកនោះអាចបាត់បង់បញ្ជិការបស់ខ្លួនក្នុងករណីក្រសួងទទួលបន្ទុកវិស័យការងារប្តឹងទៅតុលាការដើម្បីលុបបញ្ជិកា យោងតាមមាត្រា ១៨ នៃច្បាប់ស្តិពីសហជីព ។ មាត្រា ១៧ ថ្មីក៏រក្សាទុកតម្រូវការឱ្យសហជីពផ្តល់រាល់ព័ត៌មានគណនីធនាគាររបស់ខ្លួនក្នុងរយៈពេល ៤៥ ថ្ងៃគិតពីថ្ងៃទទួលបានការចុះបញ្ជី ព្រមទាំងតម្រូវការក្នុងការធ្វើបច្ចុប្បន្នកម្មព័ត៌មានដែលតម្រូវឱ្យផ្តល់នៅក្រោមច្បាប់ស្តីពីសហជីពនៅពេលដែលមានការផ្លាស់ប្តូរណាមួយ (លើកលែងថាការផ្លាស់ប្តូរចំនួនសមាជិកភាព) ក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការ ។

១១.២ ទន្ទឹមនឹងនេះដែរ ក្រុមសហជីពបានស្នើសុំឱ្យធ្វើវិសោធនកម្មលើមាត្រា ១៧ ឱ្យមាត្រានេះតម្រូវឱ្យតែការរៀបចំរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុប្រចាំឆ្នាំតាមទម្រង់យ៉ាងសាមញ្ញដែលកំណត់ដោយ

សហជីពផ្ទាល់ក្នុងគោលបំណងឱ្យសមាជិករបស់ខ្លួនបានជ្រាបជាព័ត៌មាន ។ ក្រុមសហជីពក៏បានស្នើសុំឱ្យដកចេញលក្ខខណ្ឌផ្សេងៗដែលចែងក្នុងមាត្រា ១៧ ។

១១.៣ នៅក្នុងករណីមុនៗ ខាង CFA បានបង្ហាញថា ការគ្រប់គ្រងរបស់អាជ្ញាធរសាធារណៈលើហិរញ្ញវត្ថុរបស់សហជីពមិនគួរហួសពីកាតព្វកិច្ចក្នុងការដាក់របាយការណ៍ប្រចាំ ហើយសិទ្ធិការសម្រេចចិត្តរបស់អាជ្ញាធរក្នុងការធ្វើការត្រួតពិនិត្យនិងស្នើសុំព័ត៌មាននៅពេលណាមួយអាចបង្កគ្រោះថ្នាក់ក្នុងការជ្រៀតជ្រែករដ្ឋបាលផ្ទៃក្នុងរបស់សហជីព ។[49] ខាង CFA ក៏បានបន្ថែមទៀតថាបទប្បញ្ញត្តិដែលតម្រូវឱ្យសហជីពបញ្ជូនឯកសារប្រចាំឆ្នាំទៅរដ្ឋាភិបាលហើយដែលបណ្តាលឱ្យសហជីពបាត់បង់បញ្ជិកាក្នុងករណីមិនបំពេញតាមក្នុងរយៈពេលដែលកំណត់ដោយច្បាប់ ផ្ទុយទៅនឹងសិទ្ធិរបស់សហជីពក្នុងការបង្កើតលក្ខន្តិកៈនិងវិធានរបស់ខ្លួន ហើយក្នុងការរៀបចំរដ្ឋបាលនិងសកម្មភាពរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកពីអាជ្ញាធរសាធារណៈ ។[50]

១១.៤ ទោះបីជាវិសោធនកម្មមាត្រា ១៧ ថ្មីបានប្រសើរជាងមាត្រា ១៧ ដើមដោយបានដកចេញតម្រូវការក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុនិងសកម្មភាពប្រចាំឆ្នាំជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មាត្រានេះនៅតែមិនស្របតាមស្តង់ដារការងារអន្តរជាតិទេ ។ ទោះបីជាការរៀបចំនិងការផ្សាយរបាយការណ៍សកម្មភាពនិងហិរញ្ញវត្ថុប្រចាំឆ្នាំមានផលប្រយោជន៍សម្រាប់សមាជិកដោយវាលើកកម្ពស់តម្លាភាព រឿងនេះគឺជារឿងដែលគួរសម្រេចនិងកំណត់ដោយសមាជិកផ្ទៃក្នុងនោះយោងតាមសេរីភាពរបស់ពួកគាត់ក្នុងការរៀបចំរដ្ឋបាលរបស់ខ្លួនតាមអនុសញ្ញា C87។ ដូច្នេះវាគឺទ្វេដងចំពោះតម្រូវការក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដោយស្ថាប័នសវនកម្មឯករាជដែលបានចុះបញ្ជីស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។ ស្រដៀងគ្នានេះដែរ ស្ថាប័នដែលប្រើដោយសហជីពដើម្បីធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនគឺជាបញ្ហាដែលគួរតែត្រូវបានកំណត់ដោយសហជីពផ្ទាល់។ ចំណែកការស្នើសុំពីម្ចាស់ជំនួយ កិច្ចសន្យារវាងម្ចាស់ជំនួយនិងអង្គការជាធម្មតាមានប្រការដែលតម្រូវឱ្យអង្គការបញ្ជូនទៅសវនកម្មហិរញ្ញវត្ថុ និង/ឬដាក់របាយការណ៍សវនកម្មហិរញ្ញវត្ថុជាមុន ។ ដូច្នេះ មិនចាំបាច់មានបទប្បញ្ញត្តិបន្ថែមពីករណីនេះនៅក្នុងច្បាប់ស្តីពីសហជីពទេ ។

១១.៥ លើសពីនេះទៅទៀត សហជីពគឺជាស្ថាប័នឯករាជដែលបង្កើតឡើងដោយកម្មករនិយោជិតរួមគ្នា និងមិនមែនជាស្ថាប័នចំណុះឱ្យរដ្ឋ ឬអង្គការដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលត្រូវមានកាតព្វកិច្ចផ្តល់ព័ត៌មានគណនីធនាគារធ្វើរបាយការណ៍ហិរញ្ញវត្ថុ ធ្វើរបាយការណ៍ប្រាក់ចំណូលនិងចំណាយ និងរបាយការណ៍សកម្មភាពជូនអាជ្ញាធរទេ ។ ដោយគិតពីចំណុចនេះ លទ្ធភាពក្នុងការលុបបញ្ជិកាយោងតាមមាត្រា ១៨ នៃច្បាប់ស្តីពីសហជីពក្នុងករណីសហជីពឬសមាគមនិយោជកណាមួយមិនបានផ្តល់ព័ត៌មានបែបនេះគឺហួសហេតុពីសំណាក់អាជ្ញាធរសាធារណៈ ហើយក៏ផ្ទុយទៅនឹងសេរីភាពរបស់សហជីពនិងសមាគមនិយោជកក្នុងការរៀបចំរដ្ឋបាលរបស់ខ្លួន ។

*អនុសាសន៍ ៖*

**១១.៦** ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៧ យោងតាមការស្នើសុំរបស់សហជីពដោយតម្រូវឱ្យសហជីពរៀបចំរបាយការណ៍សកម្មភាពនិងហិរញ្ញវត្ថុប្រចាំឆ្នាំតាមទម្រង់ដែលកំណត់ដោយសហជីពផ្ទាល់ដើម្បីឱ្យសមាជិករបស់ខ្លួនបានជ្រាបព័ត៌មានប៉ុណ្ណោះ ។ ក៏ត្រូវធ្វើវិសោធនកម្មលើមាត្រា ១៨ ដោយដកចេញសមត្ថភាពរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការប្តឹងទៅតុលាការការងារដើម្បីលុបបញ្ជិការបស់សហជីពបន្ទាប់ពីមិនបានអនុវត្តតាមមាត្រា ១៧ និងជំនួសដោយការពិន័យក្នុងករណីដែលសហជីពនៅតែមិនអនុវត្តតាមការជូនដំណឹងដូចចែងក្នុងមាត្រានេះរួចហើយ ។

## ១២. មាត្រា ២០ ថ្មី - លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីពនៅក្នុងសហគ្រាសឬគ្រឹះស្ថាន

**១២.១** មាត្រា ២០ ថ្មីដកចេញតម្រូវការមួយចំនួនចំពោះថ្នាក់ដឹកនាំសហជីពដែលមានចែងក្នុងមាត្រាដើមនៃច្បាប់ស្តីពីសហជីព។ ដោយបានដកចេញលក្ខខណ្ឌធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនថាមានកម្រិតវប្បធម៌យ៉ាងហោចណាស់ចេះអានចេះសរសេរអក្សរខ្មែរចំពោះពលរដ្ឋខ្មែរ ខណៈបានដកចេញលក្ខខណ្ឌធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋចំពោះពលរដ្ឋខ្មែរនិងពលរដ្ឋបរទេស ។ ពលរដ្ឋខ្មែរនៅតែត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ (ឬជាអនីតិជនដែលទទួលបានអត្តាធីនភាពយោងតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី) និងធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅច្បាស់លាស់ ។

**១២.២** បន្ថែមពីនេះទៀត ពលរដ្ឋបរទេសត្រូវចេះអាននិងចេះសរសេរអក្សរខ្មែរ បាននិងកំពុងធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិច ២ ឆ្នាំ និងមានសិទ្ធិស្នាក់នៅនិងមានទីលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជាត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។ សមត្ថភាពរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការស្នើសុំព័ត៌មានបន្ថែមទៀតបើចាំបាច់ក៏គួរត្រូវដកចេញផងដែរ ។

**១២.៣** តម្រូវការអាយុសម្រាប់ថ្នាក់ដឹកនាំសហជីពបានទទួលការរិះគន់ជាយូរមកហើយ ដោយមានសេចក្តីសម្រេចមុនៗពីខាង CFA ចំពោះមាត្រា ២០ នៃច្បាប់ស្តីពីសហជីព -មាត្រា ២៨៦ នៃច្បាប់ស្តីពីការងារដែលផ្ទុយទៅនឹងស្តង់ដារការងារអន្តរជាតិដោយមាត្រានេះកំណត់លក្ខខណ្ឌអាយុអប្បបរមាចំពោះថ្នាក់ដឹកនាំសហជិព ។[51] ថ្មីៗនេះ ខាង CEACR បានស្នើសុំដោយផ្ទាល់ទៅរាជរដ្ឋាភិបាលកម្ពុជាដើម្បីដកចេញលក្ខខណ្ឌអាយុអប្បបរមានិងការចេះអានចេះសរសេរអក្សរខ្មែរ ។[52] ក្នុងករណីផ្សេងៗទៀត ខាង

CFA ក៏បានសម្រេចថាតម្រូវការឱ្យថ្នាក់ដឹកនាំសហជីពធ្វើសេចក្ដីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅច្បាស់លាស់គឺផ្ទុយទៅនឹងអនុសញ្ញា C87 ។[53]

*អនុសាសន៍ ៖*

១២.៤ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២០ យោងតាមការស្នើសុំរបស់ខាង CEACR ដោយដកចេញលក្ខខណ្ឌតម្រូវអាយុអប្បបរមា និងការធ្វើសេចក្ដីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅច្បាស់លាស់ចំពោះពលរដ្ឋខ្មែរ ។ ក៏ត្រូវដកចេញលក្ខខណ្ឌតម្រូវការអាយុអប្បបរមា និងការតម្រូវការចេះអានចេះសរសេរចំពោះជនបរទេសដែរ ។

## ១៣. មាត្រា ២១ ថ្មី – លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជក

១៣.១ មាត្រា ២១ ថ្មីមានការផ្លាស់ប្ដូរលក្ខខណ្ឌតម្រូវចំពោះថ្នាក់ដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជកសមាគមនិយោជកដូចចែងក្នុងមាត្រា ២០ ថ្មី ចំពោះថ្នាក់ដឹកនាំសហជីព លើកលែងតែពលរដ្ឋបរទេសមិនចាំបាច់ចេះអានចេះសរសេរអក្សរយោងតាមមាត្រា ២១ ថ្មីទេ ។

១៣.២ គោលការណ៍ដែលបានពិភាក្សាក្នុងមាត្រា ២០ ថ្មីខាងលើទាក់ទងនឹងលក្ខខណ្ឌអាយុអប្បបរមានិងអាសយដ្ឋានក៏ត្រូវអនុវត្តចំពោះមាត្រានេះផងដែរ ។

*អនុសាសន៍ ៖*

១៣.៣ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២១ ដូចមាត្រា ២០ដែរដោយយោងតាមការកត់សម្គាល់របស់ខាង CEACR ដោយដកចេញការតម្រូវការអាយុនិងអាសយដ្ឋានចំពោះពលរដ្ឋខ្មែរ ព្រមទាំងតម្រូវការអាយុចំពោះជនបរទេស ។

## ១៤. មាត្រា ២៤ – ការប្រើប្រាស់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិឱ្យស្របទៅតាមលក្ខន្តិកៈនិងច្បាប់

១៤.១ មាត្រា ២៤ មិនត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះទេ។ក្រុមសហជីពក៏មិនបានស្នើសុំធ្វើវិសោធនកម្មលើមាត្រា ២៤ នេះទេ ។

១៤.២ មាត្រា ២៤ ចែងថាការដាក់បញ្ចូល និងការផ្ទេរហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សហជីពឬសមាគមនិយោជកទៅឱ្យភាគីផ្សេងទៀត ការវិនិយោគមូលនិធិរបស់សហជីពឬសមាគមនិយោជក និងរាល់ប្រតិបត្តិការអាជីវកម្មត្រឹមត្រូវតាមច្បាប់ផ្សេងទៀតដែលធ្វើឡើងដោយសហជីពឬសមាគមនិយោជកអាចធ្វើទៅបានតាមតែបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ឬលក្ខន្តិកៈរបស់សហជីពឬសមាគមនិយោជកប៉ុណ្ណោះ ។ លើសពីនេះទៀត ក្នុងករណីសង្ស័យថាមានភាពមិនប្រក្រតីក្នុងការប្រើប្រាស់និងគ្រប់គ្រងហិរញ្ញវត្ថុនោះ "ភាគីពាក់ព័ន្ធ" មានសិទ្ធិស្នើសុំធ្វើសវនកម្មដោយស្ថាប័នសវនកម្មឯករាជដែលបានចុះបញ្ជីស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

១៤.៣ ពាក្យ "ភាគីពាក់ព័ន្ធ" (ស្រដៀងគ្នានឹងមាត្រា ២៩ ថ្មីខាងក្រោម) មានភាពមិនច្បាស់លាស់ហើយមិនត្រូវបានកំណត់ដោយច្បាប់ស្តីពីសហជីពទេ ។ ច្បាប់មិននិយាយពីទំនាក់ទំនងដែលត្រូវមានដើម្បីឱ្យច្បាប់ចាត់ទុកជាថាភាគីមួយគឺជាភាគីពាក់ព័ន្ធទេ ។ ឧទាហរណ៍ តើនិយោជកតែងតែជា "ភាគីពាក់ព័ន្ធ" ចំពោះការប្រើប្រាស់ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិដោយសហជីពមូលដ្ឋានដែលបានបង្កើតក្នុងសហគ្រាសឬគ្រឹះស្ថានរបស់គាត់ទេ? តើការប្រើប្រាស់ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិដោយសហជីពនិងសមាគមនិយោជកមានទំនាក់ទំនងជាមួយនឹងវិស័យការងារដែលធ្វើឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈជា "ភាគីពាក់ព័ន្ធ" ដែរទេ?[54]

១៤.៤ យោងតាមមាត្រា ១៧ ថ្មី និង ២៧ ថ្មី ត្រូវមានចំនួនភាគរយជាក់លាក់នៃសមាជិក(ត្រូវមាន ១០ ភាគរយនៃសមាជិកសរុបចំពោះសហជីពមូលដ្ឋាននិងសមាគមនិយោជក ហើយនិង ៥ ភាគរយនៃចំនួនសមាជិកសរុបចំពោះសហព័ន្ធសហជីព សហភាពសហជីព និងសហព័ន្ធនិយោជក)ដើម្បីធ្វើការស្នើសុំធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហជីពឬសមាគមនិយោជកនោះ ។ ទោះយ៉ាងណាក៏ដោយ គ្មានតម្រូវការបែបនេះនៅក្នុងមាត្រា ២៤ ទេ ។ ដូច្នេះហាក់ដូចជាសមាជិកតែម្នាក់មានសិទ្ធិស្នើសុំឱ្យមានការសវនកម្មតាមមាត្រា ២៤ ទោះបីជាសមាជិកម្នាក់នោះមិនបំពេញតាមតម្រូវការចំនួនសមាជិកអប្បបរមាតាមមាត្រា ១៧ ថ្មី និង ២៧ ថ្មី ទេ ។

*អនុសាសន៍ ៖*

១៤.៥ ត្រូវធ្វើវិសោធនកម្មលើមាត្រា ២៤ (ឬលើមាត្រា ៤ – និយមន័យ)ដើម្បីកំណត់យ៉ាងច្បាស់លាស់ពីនិយមន័យ "ភាគីពាក់ព័ន្ធ" ។ និយមន័យនេះគួរកំណត់ដើម្បីធានាថាមានតែភាគីពិតប្រាកដជាអ្នកពាក់ព័ន្ធ (ឧទាហរណ៍ សមាជិកសហជីពឬសមាគមនិយោជក) ដែលមានសិទ្ធិស្នើសុំធ្វើសវនកម្មតាមមាត្រា ២៤ មិនមែនភាគីដែលមានទំនាក់ទំនងតែមួយមុខគត់ក្នុងការប្រើប្រាស់ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់សហជីពឬសមាគមនិយោជក ។

## ១៥. មាត្រា ២៧ ថ្មី – ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ

១៥.១ មាត្រា ២៧ ថ្មីតម្រូវឱ្យសហជីពនិងសមាគមនិយោជកថែរក្សាកំណត់ត្រាហិរញ្ញវត្ថុស្របតាមទម្រង់បែបបទដែលកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ ហើយក៏បន្ថែមតម្រូវការឱ្យកំណត់ត្រានេះត្រូវបានធ្វើសវនកម្មក្នុងករណីមានការស្នើសុំពីចំនួនភាគរយសមាជិកតិច (១០ ភាគរយនៃសមាជិកសរុបចំពោះសហជីពមូលដ្ឋាននិងសមាគមនិយោជក និង ៥ ភាគរយចំពោះសហព័ន្ធសហជីព សហភាពសហជីព និងសហព័ន្ធនិយោជក) ឬពីម្ចាស់ជំនួយណាមួយ ។ សហជីពឬសមាគមនិយោជកដែលមិនបំពេញតាមលក្ខខណ្ឌនៃមាត្រានេះជាដំបូងត្រូវទទួលការព្រមានហើយក្រោយមកទទួលពិន័យជាប្រាក់យោងតាមមាត្រា ៧៨ នៃច្បាប់ស្តីពីសហជីព ។

១៥.២ ទន្ទឹមនឹងនេះ ក្រុមសហជីពបានស្នើសុំឱ្យធ្វើវិសោធនកម្មលើមាត្រា ២៧ ដូចបានស្នើចំពោះមាត្រា ១៧ ដោយតម្រូវឱ្យសហជីពនិងសមាគមនិយោជកគ្រាន់តែថែរក្សាកំណត់ត្រាហិរញ្ញវត្ថុតាមទម្រង់យ៉ាងសាមញ្ញដែលកំណត់ដោយសហជីពឬសមាគមនិយោជកផ្ទាល់ក្នុងគោលបំណងឱ្យសមាជិករបស់ខ្លួនជ្រាបជាព័ត៌មាន ។

១៥.៣ ស្របជៀងគ្នានឹងការពិភាក្សាអំពីមាត្រា ១៧ ថ្មីខាងលើនៅក្នុងកថាខណ្ឌលេខ ១១.៤ ខាងលើ ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ ហើយជាពិសេសទម្រង់នៃការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុនោះគឺជារឿងដែលគួរសម្រេចចិត្តដោយសហជីពឬសមាគមនិយោជកដោយផ្ទាល់យោងតាមសេរីភាពរបស់សហជីពនិងសមាគមនិយោជកក្នុងការរៀបចំរដ្ឋបាលរបស់ខ្លួនតាមមាត្រា ៣ នៃអនុសញ្ញា C87 ។[55] ស្របជៀងគ្នាជាមួយមាត្រា ១៧ ថ្មីផងដែរ ការស្នើសុំធ្វើសវនកម្មពីម្ចាស់ជំនួយគឺជារឿងដែលគួរសម្រេចចិត្តតាមរយៈកិច្ចសន្យាដែលចុះហត្ថលេខារវាងភាគីនោះ ។

*អនុសាសន៍ ៖*

១៥.៤ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២៧ ដែលស្របជៀងគ្នានឹងមាត្រា ១៧ ដោយតម្រូវឱ្យសហជីពនិងសមាគមនិយោជកថែរក្សាកំណត់ត្រាហិរញ្ញវត្ថុតាមទម្រង់កំណត់ដោយខ្លួនឯង ដើម្បីឱ្យសមាជិករបស់ខ្លួនបានជ្រាបជាព័ត៌មាន ។

## ១៦. មាត្រា ២៨ ថ្មី – ការរំលាយសហជីពឬសមាគមនិយោជក

១៦.១ មាត្រា ២៨ ថ្មីផ្លាស់ប្តូរកថាខណ្ឌទីពីរ ដោយឥឡូវចែងថាសហជីពមួយត្រូវបានរំលាយដោយស្វ័យប្រវត្តិក្នុងករណីដែលសហគ្រាសឬគ្រឹះស្ថានត្រូវបានបិទលែងដំណើរការជាស្ថាពរនិងបានទូទាត់ជាស្ថាពរនូវប្រាក់ឈ្នួលនិងប្រាក់អត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត ។ មាត្រា ២៨ ថ្មីក៏ផ្លាស់ប្តូរពាក្យក្នុងកថាខណ្ឌទី៣ "តុលាការការងារ" ទៅ "តុលាការ" (ប៉ុន្តែមាត្រា ២៩ ថ្មីនៅតែប្រើប្រាស់ពាក្យ "តុលាការការងារ") ។

១៦.២ កន្លងមកខាង CEACR បានស្នើសុំឱ្យរាជរដ្ឋាភិបាលដកចេញកថាខណ្ឌទីពីរនៃមាត្រា ២៨ ដោយលើកឡើងថាសហជីពអាចមានផលប្រយោជន៍ស្របច្បាប់ក្នុងការបន្តប្រតិបត្តិការក្រោយពីការបិទសហគ្រាសឬគ្រឹះស្ថាន(ឧទាហរណ៍ ដើម្បីការពារការទាមទារណាមួយរបស់សមាជិកសហជីពរបស់ខ្លួន) ។[56]

១៦.៣ កថាខណ្ឌទីពីរនៃមាត្រា ២៨ ថ្មីមិនឆ្លើយតបទៅនឹងកំណត់សម្គាល់របស់ខាង CEACR ទេ ។ ដូចបានលើកឡើងដោយខាង CEACR សហជីពអាចមានផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់ក្នុងការពារទាមទាររបស់សមាជិករបស់ខ្លួនក្រោយពីការបិទសហគ្រាសឬគ្រឹះស្ថាន ក្រៅពីការទាមទារទាក់ទងនឹងការទូទាត់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងៗ ។ ឧទាហរណ៍ ក្នុងករណីសហជីពប្រហែលជាចង់ប្តឹងក្រុមហ៊ុនសម្រាប់ការកាត់ភាគទានសហជីពដែលមិនត្រឹមត្រូវ (ឧ. កាត់ភាគទានសហជីពពីប្រាក់ឈ្នួលរបស់សមាជិកតែផ្ញើប្រាក់នោះជូនសហជីពផ្សេងទៀតដោយគ្មានការអនុញ្ញាតត្តិ) ។ ទោះយ៉ាងណាក៏ដោយ យោងតាមកថាខណ្ឌទីពីរនៃមាត្រា ២៨ ថ្មី ក្នុងករណីដែលក្រុមហ៊ុនបានទូទាត់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិតដូចបានកើតឡើងនេះ សហជីពនោះត្រូវបានរារាំងពីលើកឡើងការទាមទារបែបនេះ ។

១៦.៤ ក្រុមសហជីពក៏បានស្នើសុំការដកចេញកថាខណ្ឌទីបីនៃមាត្រា ២៨ ដែលផ្តល់សិទ្ធិជូនតុលាការក្នុងការរំលាយសហជីពឬសមាគមនយោជកយោងតាមមាត្រា ២៩ ។ ក្រុមសហជីពមិនបានផ្តល់មូលហេតុណាមួយក្នុងឯកសារទេ ប៉ុន្តែមូលហេតុមួយប្រហែលជាអាចទាក់ទងនឹងការព្រួយបារម្ភអំពី មន្ត្រីជំនាញរបស់សាលាដំបូងទាក់ទងនឹងវិវាទការងារ ។[57] ទោះបីជាមាត្រា ២៩ ថ្មីនៅតែប្រើប្រាស់ពាក្យ "តុលាការការងារ" បន្ទាប់ពីមានការប្រកាសពីលោកនាយករដ្ឋមន្ត្រីហ៊ុន សែនថាមិនចាំបាច់មានតុលាការការងារនៅក្នុងប្រទេសកម្ពុជាទេ[58] ហាក់ដូចជាបណ្តឹងទាំងនោះនៅតែត្រូវបន្តកាត់ក្តីដោយសាលាដំបូង ។ បើសិនជាមន្ត្រីសាលាដំបូងខ្វះសមត្ថភាពមែនក្នុងការកាន់វិវាទការងារ អំណាចក្នុងការរំលាយសហជីពយោងតាមមាត្រា ២៨ ថ្មី និង ២៩ ថ្មី នៃច្បាប់ស្តីពីសហជីព អាចប្រគល់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ការពង្រឹង និងការផ្តល់អំណាចជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺជារឿងដែលរាជរដ្ឋាភិបាលកន្លងមកបានលើកឡើងទៅខាង CEACR ថារាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តក្នុងការធ្វើដូច្នេះ ។[59]

*អនុសាសន៍ ៖*

១៦.៥ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២៨ យោងតាមកំណត់សម្គាល់របស់ខាង CEACR ដោយដក ចេញកថាខណ្ឌទីពីរដើម្បីធានាថាការរំលាយសហជីពត្រូវតែធ្វើឡើងតាមនីតិវិធីរបស់ខ្លួនដូចកំណត់ ដោយលក្ខន្តិកៈរបស់សហជីព ឬដោយសេចក្តីសម្រេចរបស់តុលាការប៉ុណ្ណោះ ។ រាជរដ្ឋាភិបាលក៏គួរ ពិចារណាធ្វើវិសោធនកម្មលើកថាខណ្ឌទីបីនៃមាត្រា ២៨ (រួមជាមួយមាត្រា ២៩) ដើម្បីផ្តល់អំណាច ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការរំលាយសហជីពជំនួសឱ្យសាលាដំបូង ។

## ១៧. មាត្រា ២៩ ថ្មី – មូលហេតុនៃការរំលាយចោលដោយតុលាការការងារ

១៧.១ មាត្រា ២៩ ថ្មីដកចេញកថាខណ្ឌ "គ" តាមការស្នើសុំរបស់ខាង CEACR ។[60] ទោះយ៉ាងណាក៏ដោយ មាត្រា ២៩ ថ្មីនៅតែឱ្យ "ភាគីពាក់ព័ន្ធ" ឬ៥០ ភាគរយនៃសមាជិកសរុបនៃសហជីពឬសមាគម និយោជកប្តឹងទៅតុលាការការងារដើម្បីរំលាយសហជីពឬសមាគមនិយោជក ។ ពាក្យ "ភាគីពាក់ព័ន្ធ" មិនបានកំណត់ទេ ។ ដោយមានការដកចេញកថាខណ្ឌ "គ" នៃមាត្រា ២៩ តុលាការការងារសព្វថ្ងៃនេះ គ្រាន់តែមានអំណាចរំលាយសហជីពឬសមាគមនិយោជកក្នុងករណីការបង្កើតឬសកម្មភាពនានារបស់ សហជីពឬសមាគមនិយោជកមានលក្ខណៈផ្ទុយនឹងច្បាប់ឬគោលដៅនៃសហជីពឬសមាគមនិយោជក ដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់ខ្លួន ។ លើសពីនេះទៀត សហជីពអាចរំលាយដោយតុលាការ ការងារបានក្នុងករណីដែលសហជីពនោះមិនមានលក្ខណៈឯករាជ្យពីនិយោជក ហើយជាក់ស្តែងមិន អាចស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួន ។

១៧.២ ដូចគ្នានឹងមាត្រា ២៤ ខាងលើ ពាក្យ "ភាគីពាក់ព័ន្ធ" មិនបានកំណត់ហើយមានភាពមិនច្បាស់លាស់ ណាស់ ។ ឧទាហរណ៍ តើនិយោជកជា "ភាគីពាក់ព័ន្ធ" ចំពោះការដាក់ពាក្យបណ្តឹងរំលាយសហជីពមូល ដ្ឋាននៅក្នុងសហគ្រាសឬគ្រឹះស្ថានរបស់ខ្លួនទេ ? តើក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬសហ ជីពផ្សេងទៀតនៅក្នុងសហគ្រាសឬគ្រឹះស្ថានជាភាគីពាក់ព័ន្ធ ? ដូចបានពិភាក្សានៅក្នុងកថាខណ្ឌ លេខ ១៤.៣ ខាងលើ ច្បាប់ស្តីពីសហជីពមិនមិនបានផ្តល់ការណែនាំអំពីអ្វីដែលមានលក្ខណៈគ្រប់ គ្រាន់ដើម្បីឱ្យច្បាប់ចាត់ទុកជាថាភាគីមួយគឺជា "ភាគីពាក់ព័ន្ធ" ដើម្បីឱ្យភាគីនោះដាក់ពាក្យបណ្តឹង ដែលបណ្តាលឱ្យមានស្ថានភាពមួយដែលក្រុមភាគីច្រើនអាចបកស្រាយថាជាភាគីពាក់ព័ន្ធ ។

១៧.៣ ក្រុមសហជីពបានស្នើសុំឱ្យធ្វើវិសោធនកម្មលើមាត្រា ២៩ ដើម្បីកើនឡើងចំនួនអប្បបរមានៃសមាជិក ដែលចាំបាច់ដើម្បីប្តឹងទៅតុលាការពី ៥០ ភាគរយ ទៅពីរភាគបីនៃសមាជិកសរុប ។ លើសពីនេះទៀត ក្រុមសហជីពក៏បានស្នើសុំឱ្យដកចេញកថាខណ្ឌ "ខ" ដែលឱ្យមានការរំលាយសហជីពក្នុងករណីដែល សហជីពនោះមិនមានលក្ខណៈឯករាជ្យពីនិយោជក ហើយជាក់ស្តែងមិនអាចស្តារឡើងវិញនូវភាពឯក រាជ្យរបស់ខ្លួន ។ ក្រុមសហជីពបានលើកឡើងការស្នើសុំនេះដោយមូលហេតុថាពាក្យដែលប្រើប្រាស់

ក្នុងកថាខណ្ឌ "ខ" មានភាពមិនច្បាស់លាស់ ហើយដូច្នេះកថាខណ្ឌនេះអាចប្រើប្រាស់បានដើម្បីជាមូលដ្ឋានរំលាយសហជីព ។

**១៧.៤** តាមពិត ពាក្យនៃទាំងកថាខណ្ឌ "ក" និង "ខ" មានភាពមិនច្បាស់លាស់ទាំងពីរ ។ ឧទាហរណ៍ កថាខណ្ឌ "ក" ឱ្យមានការរំលាយសហជីពឬសមាគមនិយោជកក្នុងករណីដែលសកម្មភាពរបស់ខ្លួនមានលក្ខណៈផ្ទុយទៅនឹងច្បាប់ឬគោលដៅដូចចែងក្នុងលក្ខន្តិកៈរបស់ខ្លួន ។ ប៉ុន្តែ មិនមានការកំណត់អំពីការរំលោភបំពានក្នុងកថាខណ្ឌ "ក" ដែលបណ្តាលឱ្យមានការរំលាយ ដែលបង្ហាញថាការការរំលោភបំពានតូចតាចមួយអាចបណ្តាលឱ្យមានការរំលាយសហជីពឬសមាគមនិយោជក ។ ក្នុងករណីមុនៗខាង CFA បានចែងថាការរំលាយសហជីពគឺជាវិធានការមួយដែលគួរតែកើតឡើងតែក្នុងករណីធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ ។[61] ទោះយ៉ាងណាក៏ដោយ ផ្អែកលើពាក្យដែលប្រើប្រាស់នៅក្នុងកថាខណ្ឌ "ក" ការរំលោភបំពានតូចមួយអាចបណ្តាលឱ្យមានការរំលាយសហជីពឬសមាគមនិយោជកបាន ។ លើសពីនេះទៀត ទោះបីជាមាត្រា ២៩ ថ្មីផ្តល់អំណាចជូនតុលាការការងារក្នុងការកំណត់ពេលវេលាសម្រាប់ឱ្យសហជីពឬសមាគមនិយោជកធ្វើការកែតម្រូវកង្វះខាតទាំងឡាយដូចមានចែងក្នុងកថាខណ្ឌ "ក" គ្មានការកំណត់ពេលវេលាច្បាស់លាសចែងក្នុងច្បាប់ទេ។ ហើយនេះដែលអាចបណ្តាលឱ្យមានករណីរើសអើង ដោយមានសហជីពឬសមាគមនិយោជកខ្លះដែលតុលាការកំណត់ពេលវេលាយូរជាងសហជីពឬសមាគមនិយោជកផ្សេងទៀតសម្រាប់ការធ្វើកែតម្រូវកង្វះខាត ។

**១៧.៥** ដូចបានលើកឡើងដោយក្រុមសហជីព កថាខណ្ឌ "ខ" មានភាពមិនច្បាស់លាស ។ ទោះបីជាភាពឯករាជ្យពីនិយោជកគឺចាំបាច់យោងតាមមាត្រា ២ នៃអនុសញ្ញា C98[62] ពាក្យដែលប្រើប្រាស់ក្នុងកថាខណ្ឌ "ខ" មិនកំណត់អំពីអ្វីដែលជាការកង្វះខាតឯករាជ្យពីនិយោជក ឬកាលៈទេសៈដែលត្រូវបញ្ជាក់ដើម្បីសម្រេចថាសហជីពនោះមិនអាចស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួន ។ ឧទាហរណ៍ បើថ្នាក់ដឹកនាំសហជីពមូលដ្ឋានម្នាក់ទទួលយកសំណូកពីនិយោជកជាប្រចាំ នេះជារឿងដែលបង្ហាញថាសហជីពមិនមានលក្ខណៈឯករាជ្យពីនិយោជកទេ។ ប៉ុន្តែ មាត្រា ២៩ ថ្មីមិនកំណត់អំពីរបៀបដែលតុលាការសម្រេចថាតើសហជីពនោះអាចស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួនឬទេ ។

**១៧.៦** ក៏គួរកត់សម្គាល់ថា កថាខណ្ឌ "ខ" និយាយតែពីភាពឯករាជ្យពីនិយោជក តែមិននិយាយពីគណបក្សនយោបាយឬរដ្ឋាភិបាលសោះ ។ ទន្ទឹមនឹងបទប្បញ្ញត្តិដែលរារាំងសហជីពពីសកម្មភាពនយោបាយដើម្បីលើកកម្ពស់គោលបំណងរបស់ខ្លួនផ្ទុយទៅនឹងសេរីភាពក្នុងការបង្កើតសមាគម[63] រដ្ឋាភិបាលមិនគួរព្យាយាមផ្លាស់ប្តូរចលនាសហជីពទៅជាឧបករណ៍ដើម្បីគោលដៅនយោបាយទេ ហើយក៏មិនគួរជ្រៀតជ្រែកដល់មុខងារធម្មតារបស់ចលនាសហជីពដោយសារចលនានោះមានទំនាក់ទំនងដែលបានបង្កើតដោយសេរីជាមួយគណបក្សនយោបាយមួយ ។[64] ដូច្នេះ ខណៈច្បាប់មិនគួរហាមឃាត់ទំនាក់ទំនងរវាងសហជីពនិងគណបក្សនយោបាយ កថាខណ្ឌ "ខ" ក៏គួរពិចារណាពីភាពឯករាជ្យពីរដ្ឋាភិបាលដែរ ។

*អនុសាសន៍ ៖*

**១៧.៧** ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ២៩ ដើម្បីឱ្យកថាខណ្ឌ ក និង ខ មានភាពច្បាស់លាស់ជាងមុន ។ ជាពិសេសត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌ ក ដើម្បីធានាថាការបំពានតូចតាចមិនបណ្តាលឱ្យមានការរំលាយចោលសហជីពឬសមាគមនិយោជក ហើយការរំលាយចោលជាជម្រើសចុងក្រោយបន្ទាប់ពីមានការរំលោភច្បាប់ដ៏ធ្ងន់ធ្ងរ ។ ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌ ខ ដើម្បីឱ្យវាមានភាពច្បាស់លាស់ជាងមុន ជាពិសេសទាក់ទងនឹងនិយមន័យនៃលក្ខណៈឯករាជ្យពីនយោជក ហើយកាលៈទេសៈដែលត្រូវបញ្ជាក់ដើម្បីឱ្យរកឃើញថាសហជីពនោះមិនអាចស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួន ។ ថែមទាំងត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌ ខ ដើម្បីឱ្យតុលាការរំលាយចោលសហជីពដែលមិនមានលក្ខណៈឯករាជ្យពីរដ្ឋាភិបាលក្នុងករណីសហជីពនោះជាក់ស្តែងមិនអាចស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួន ។ ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌចុងក្រោយនៃមាត្រា ២៩ ដោយកំណត់ពេលវេលាសម្រាប់ការធ្វើកែតម្រូវកង្វះខាតទាំងឡាយដូចមានចែងក្នុងកថាខណ្ឌ ក និង ខ ។

## ១៨. មាត្រា ៣៨ – សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះជាបេក្ខជន

**១៨.១** មាត្រា ៣៨ មិនត្រូវបានធ្វើវិសោធនកម្មទេថ្មីៗនេះ ហើយសហជីពក៏មិនបានស្នើសុំឱ្យធ្វើវិសោធនកម្មលើមាត្រា ៣៨ ទេ ។

**១៨.២** មាត្រា ៣៨ កំណត់ពីលក្ខខណ្ឌតម្រូវដើម្បីមានសិទ្ធិបោះឆ្នោតនិងឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន ។ យោងតាមមាត្រានេះ កម្មករទាំងអស់ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយដែលបានធ្វើការយ៉ាងតិចពី ៣ ខែក្នុងសហគ្រាសឬគ្រឹះស្ថាន និងអ្នកមិនកំពុងទទួលទោសស្តីពីការដកសិទ្ធិបោះឆ្នោត។ ចំពោះអ្នកដែលចង់ឈរឈ្មោះជាបេក្ខជន ពួកគាត់ក៏ត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ បានធ្វើការយ៉ាងតិច ៣ ខែក្នុងសហគ្រាសឬគ្រឹះស្ថាន ហើយក៏ត្រូវមានកម្រិតវប្បធម៌ទូទៅយ៉ាងហោចណាស់ចេះអានចេះសរសេរអក្សរខ្មែរ ។

**១៨.៣** កន្លងមកខាង CEACR បានស្នើសុំដោយផ្ទាល់ឱ្យរាជរដ្ឋាភិបាលធ្វើវិសោធនកម្មលើមាត្រា ៣៨ ដើម្បីដកចេញលក្ខខណ្ឌអាយុនិងការតម្រូវ ឱ្យចេះអានចេះសរសេរអក្សរខ្មែរ ។[65] គោលការណ៍ដែលបានពិភាក្សានៅក្នុងកថាខណ្ឌលេខ ១២.៣ ខាងលើទាក់ទងនឹងលក្ខខណ្ឌតម្រូវអប្បបរមាតាមមាត្រា ២០ ថ្មី និង ២១ ថ្មីនៃច្បាប់ស្តីពីសហជីពក៏ត្រូវអនុវត្តចំពោះលក្ខខណ្ឌអាយុអប្បបរមាដូចចែងក្នុងមាត្រា ៣៨ ផងដែរ ។

**១៨.៤** លក្ខខណ្ឌអតីតភាពការងារដែលកំណត់ដោយមាត្រា ៣៨ ក៏ផ្ទុយទៅនឹងស្តង់ដារការងារអន្តរជាតិ ។ មាត្រា ៣ នៃអនុសញ្ញា C87 ទទួលស្គាល់សិទ្ធិរបស់កម្មករនិយោជិតក្នុងការជ្រើសរើសអ្នកតំណាងរបស់

ខ្លួនដោយសេរីភាពពេញលេញ ។ កន្លងមកខាង CFA បានចែងថាលក្ខខណ្ឌអតីតភាពការងារសម្រាប់ថ្នាក់ដឹកនាំសហជីពគ្មួយទៅនឹងសិទ្ធិដែលផ្តល់ដោយមាត្រា ៣ នៃអនុសញ្ញា C87 ។[66] ប្រតិភូបុគ្គលិកក៏ជាអ្នកតំណាងកម្មករនិយោជកនៅក្នុងកន្លែងការងារ ដូច្នេះការរារាំងកម្មករនិយោជិតដែលបានធ្វើការតិចជាង ៣ ខែក្នុងសហគ្រាសឬគ្រឹះស្ថានពីការបោះឆ្នោត ឬការឈរឈ្មោះជាបេក្ខជនជាការរំលោភសិទ្ធិរបស់ពួកគាត់ក្នុងការជ្រើសរើសតំណាងរបស់ខ្លួនដោយមានសេរីភាពពេញលេញ ។

*អនុសាសន៍ ៖*

១៨.៥ ត្រូវធ្វើវិសោធនកម្មលើមាត្រា ៣៨ ដោយដកចេញតម្រូវការអាយុអប្បបរមា ចេះអានចេះសរសេរ និងអតីតភាពការងារដែលកំពុងកំណត់ដោយមាត្រានេះ ។

## ១៩. មាត្រា ៤៣ – ការការពារប្រតិភូបុគ្គលិក

១៩.១ មាត្រា ៤៣ មិនត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះទេ ប៉ុន្តែក្រុមសហជីពបានស្នើសុំឱ្យធ្វើវិសោធនកម្មលើមាត្រ៤៣។

១៩.២ មាត្រា ៤៣ ចែងថារាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួនអាចធ្វើបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ ។ ការការពារនេះក៏ត្រូវអនុវត្តចំពោះអតីតប្រតិភូបុគ្គលិកក្រោយពេលបញ្ចប់អាណត្តិរបស់ខ្លួនរយៈពេល ៣ ខែ និងក្នុងរយៈពេល ៣ ខែផងដែរចំពោះអតីតបេក្ខជនមិនជាប់ឆ្នោតក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត ។ អធិការការងារមានរយៈពេល ១ ខែដើម្បីចេញសេចក្តីសម្រេចក្រោយទទួលពាក្យបណ្តឹងពីនិយោជក ។ បន្ទាប់ពីទទួលសេចក្តីសម្រេចនោះ និយោជក កម្មករ ឬសហជីពមានរយៈពេល ២ ខែដើម្បីតវ៉ាទៅរដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ ហើយរដ្ឋមន្ត្រីក៏មានរយៈពេល ២ ខែដើម្បីចេញសេចក្តីសម្រេចក្រោយពីទទួលការតវ៉ានោះ។

១៩.៣ ក្រុមសហជីពបានស្នើសុំការធ្វើវិសោធនកម្មមួយចំនួនចំពោះមាត្រា ៤៣ ។ ក្នុងករណីដែលអធិការការងារបង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិតចូលធ្វើការវិញ ក្រុមសហជីពបានស្នើសុំតម្រូវឱ្យនិយោជកទទួលយកកម្មករនិយោជិតនោះចូលធ្វើការវិញភ្លាមៗ ហើយទូទាត់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងៗគិតពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ ហើយក៏បានស្នើសុំឱ្យអធិការការងារចុះទៅសហគ្រាសឬគ្រឹះស្ថានដោយផ្ទាល់ដើម្បីអនុវត្តសេចក្តីសម្រេចនេះ ។ ក្រុមសហជីពបានស្នើសុំឱ្យការតវ៉ាទាំងអស់ទៅនឹងសេចក្តីសម្រេចនេះត្រូវបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងរយៈពេល ៤៨ ម៉ោងក្រោយពីទទួលការតវ៉ា ។ ក្នុងករណីដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបង្គាប់ឱ្យនិយោជកទទួលយកកម្មករចូលធ្វើការវិញ ក្រុមសហជីពបានស្នើ

សុំឱ្យរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈចេញសេចក្តីបង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិតចូលធ្វើការវិញ ហើយទូទាត់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងៗគិតពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ ។

១៩.៤ ការស្នើសុំរបស់ក្រុមសហជីពនឹងពន្លឿននីតិវិធីតាមមាត្រា ៤៣ ។ យោងតាមនីតិវិធីបច្ចុប្បន្នដែលកំណត់ដោយមាត្រា ៤៣ អាចមានរយៈពេល ៥ ខែចាប់ពីថ្ងៃដាក់ការស្នើសុំរបស់និយោជករហូតដល់ថ្ងៃចេញសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ។ ប្រៀបធៀប ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល ១៥ ថ្ងៃក្រោយពីទទួលបណ្តឹង ។[67] ការពន្លឿននីតិវិធីដោះស្រាយតាមមាត្រា ៤៣ នឹងផ្តល់ផលប្រយោជន៍ច្រើនដល់កម្មករនិយោជិតដែលភាគច្រើនមិនបានប្រាក់ខែខណៈពេលពួកគាត់រង់ចាំលទ្ធផលនៃសំណុំរឿងរបស់គាត់ ។ រាជរដ្ឋាភិបាលកន្លងមកបានលើកឡើងទៅខាង CEACR ថារាជរដ្ឋាភិបាលមានគោលបំណងក្នុងបើកសិទ្ធិឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលវិវាទបុគ្គលដូចវិវាទពាក់ព័ន្ធនឹងមាត្រា ៤៣ នៃច្បាប់ស្តីពីសហជីព ។[68] រដ្ឋាភិបាលក៏បានបង្ហាញពីចេតនារបស់ខ្លួនក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយលើវិវាទបុគ្គលបាន។[69] ការផ្តល់អំណាចជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរបៀបនេះក៏ស្របតាមគោលការណ៍ដែលរដ្ឋាភិបាលទទួលខុសត្រូវចំពោះការធានាថានីតិវិធីជាតិត្រូវបានពន្លឿន មិនលំអៀង ហើយត្រូវបានពិចារណាបែបនេះដោយភាគីពាក់ព័ន្ធ ។[70]

១៩.៥ ក្នុងករណីមុនៗ ខាង CFA បានរិះគន់ការពន្យាពេលក្នុងការដោះស្រាយករណីការបញ្ចប់កិច្ចសន្យាការងារមិនស្របច្បាប់នៅក្នុងប្រទេសកម្ពុជា[71] ហើយក៏បានអំពាវនាវច្រើនដងឱ្យរាជរដ្ឋាភិបាល "ចាត់វិធានការដោយគ្មានការពន្យាពេលក្នុងការអនុម័តក្របខ័ណ្ឌច្បាប់ដែលសមស្របដើម្បីធានាថាកម្មករនិយោជិតមានការការពារដោយប្រសិទ្ធិភាពប្រឆាំងអំពើការរើសអើងសហជីពរួមបញ្ចូលការផ្តល់នូវទណ្ឌកម្មដែលអាចទទួលយកបាននិងការសម្រេចលឿន ចុងក្រោយនិងជាប់កាតព្វកិច្ច ។"[72]

១៩.៦ ការផ្តល់អំណាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចលើការតវ៉ាសេចក្តីសម្រេចរបស់អធិការការងារនឹងធ្វើឱ្យនីតិវិធីដោះស្រាយវិវាទការងារសាមញ្ញជាងមុន ។ នីតិវិធីបច្ចុប្បន្នអាចបណ្តាលឱ្យមានករណីដែលការបញ្ឈប់ប្រតិភូបុគ្គលិកត្រូវបានប្តឹងពីរដង ៖ មួយដងប្តឹងទៅរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយមួយដងទៀតទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ឧទាហរណ៍ នៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៩ ប្រតិភូបុគ្គលិក ២ នាក់ត្រូវបានបញ្ឈប់នៅរោងចក្រ ម៉ូណូភា (ខេមបូឌា) ខូ អិលធីឌី ក្រោយពីក្រុមហ៊ុនបានទទួលការអនុញ្ញាតបញ្ឈប់បុគ្គលិកពីរនាក់នោះពីនាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺកាលពីថ្ងៃទី ១៩ ខែវិច្ឆិកា ។ ប្រតិភូបុគ្គលិកពីរនាក់នោះបានប្តឹងទៅនាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺតាំងពីថ្ងៃទី ១៤ ខែវិច្ឆិកា ក្រោយពីនិយោជកបានព្យួរការងាររបស់ពួកគាត់ខណៈរង់ចាំសេចក្តីសម្រេចរបស់អធិការការងារ ។ ប៉ុន្តែ ប្រតិភូបុគ្គលិកពីរនាក់នេះក៏បានតវ៉ាទៅនឹងសេចក្តីសម្រេចរបស់អធិការការងារទៅរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជា

ជីវៈនៅថ្ងៃទី ២២ ខែវិច្ឆិកា ។ ដូច្នេះ នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានជម្រះដោយបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកទទួលយកពួកគាត់ចូលធ្វើការវិញដោយសារវិវាទនេះកំពុងស្ថិតនៅក្រោមនីតិវិធីរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈដោយសារតែរយៈពេល ២ ខែ ដែលកំណត់ដោយច្បាប់សម្រាប់រដ្ឋមន្ត្រីសម្រេចលើបណ្ដឹងតវ៉ាមិនទាន់ផុតរលត់នៅឡើយទេ ។[73] លុះដល់ថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ ទើបរដ្ឋមន្ត្រីចេញសេចក្ដីសម្រេចនោះ។

*អនុសាសន៍ ៖*

១៩.៧ ត្រូវធ្វើវិសោធនកម្មលើមាត្រា ៤៣ យោងតាមការស្នើសុំរបស់សហជីពដោយផ្ដល់អំណាចជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងការដោះស្រាយការតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់អធិការការងារដើម្បីធ្វើឱ្យនីតិវិធីដំណោះស្រាយលឿននិងសាមញ្ញជាងមុនសម្រាប់ករណីការបញ្ឈប់ប្រតិភូបុគ្គលិក ។

## ២០. មាត្រា ៤៧ - បណ្ដឹងតវ៉ានៅលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

២០.១ មាត្រា ៤៧ មិនត្រូវបានវិសោធនកម្មទេ ប៉ុន្តែក្រុមសហជីពបានស្នើសុំឱ្យមានវិសោធនកម្មលើមាត្រា ៤៧ ។

២០.២ មាត្រា ៤៧ តម្រូវឱ្យការតវ៉ាផ្សេងៗទាក់ទងនឹងការបោះឆ្នោត សិទ្ធិឈរឈ្មោះ និងភាពមិនត្រឹមត្រូវនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកត្រូវដាក់ជូនតុលាការការងារដោះស្រាយ ។ ចំណែកក្រុមសហជីពបានស្នើសុំធ្វើវិសោធនកម្មលើមាត្រា ៤៧ ឱ្យការតវ៉ាផ្សេងៗទាក់ទងនឹងការបោះឆ្នោត សិទ្ធិឈរឈ្មោះ និងភាពមិនត្រឹមត្រូវនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកត្រូវដាក់ជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារដោះស្រាយក្នុងរយៈពេល ១៥ ថ្ងៃ ។

២០.៣ ការស្នើសុំរបស់ក្រុមសហជីពនឹងជួយពន្លឿននីតិវិធីដោះស្រាយតាមមាត្រា ៤៧ ។ ឥឡូវនេះគ្មានការកំណត់ពេលវេលាសម្រាប់ការចេញសេចក្ដីសម្រេចយោងតាមមាត្រា ៤៧ ក្រោយពីមានការតវ៉ាទៅតុលាការការងារ។ ដោយមានការប៉ះពាល់ថាកម្មករជាញឹកញាប់ត្រូវស្វែងរកការជំនួយក្រៅពីនីតិវិធីក្នុងស្រុកដើម្បីដោះស្រាយការតវ៉ាទាក់ទងនឹងការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ។ ឧទាហរណ៍ នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៩ អ្នកគ្រប់គ្រងនៅរោងចក្រ ធៀន ស៊ុង ហ្គាមេន (ខេមបូឌា) ខូ អិលធីឌី បានរៀបចំការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកដោយគ្មានជូនដំណឹងត្រឹមត្រូវដល់កម្មករនិយោជិត[74] ហើយដោយមិនបានទាក់ទងត្រឹមត្រូវអំពីដំណើរការតែងតាំងដល់កម្មករ ។ ក្រោយពីមាន

ការបោះឆ្នោតនេះ សហជីពមូលដ្ឋានដែលជាសមាជិកនៃសហព័ន្ធសហជីពកម្ពុជា (CATU) បានប្តឹងទៅក្រុមហ៊ុនបញ្ញាទិញ New Balance ជំនួសប្តឹងទៅតុលាការតាមនីតិវិធីកំណត់ដោយមាត្រា ៤៧ ក្រុមហ៊ុនបញ្ញាទិញនេះបានធ្វើអន្តរាគមន៍ដោយបានផ្លាស់ប្តូរលទ្ធផល ឱ្យក្រុមហ៊ុនរៀបចំការបោះឆ្នោតថ្មីក្នុងរយៈពេល១ សប្តាហ៍ក្រោយពីសហជីពបានដាក់ពាក្យបណ្តឹង ។

២០.៤ កម្មករនិងសហជីពគួរទទួលបានយុត្តិធម៌យ៉ាងលឿនក្នុងករណីមានបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក សិទ្ធិឈរឈ្មោះ និងភាពមិនត្រឹមត្រូវនៃការបោះឆ្នោត ។ យុត្តិធម៌នេះជាចម្បងគួរអាចទទួលបានតាមរយៈយន្តការដំណោះស្រាយក្នុងស្រុក ។ ដូច្នេះ កម្មករនិងសហជីពគួរមានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងពាក់ព័ន្ធការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក សិទ្ធិឈរឈ្មោះ និងភាពមិនត្រឹមត្រូវនៃការបោះឆ្នោតជូននាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ វិវាទទាំងនេះក៏គួរតែត្រូវបានចាត់ថ្នាក់ជាវិវាទការងាររួមដូច្នេះក្នុងករណីដែលមិនអាចដោះស្រាយផ្សះផ្សាបានដោយមន្ត្រីមន្ទីរបានទេ វិវាទទាំងនេះគួរបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ការផ្តល់អំណាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចលើការតវ៉ាតាមមាត្រា ៤៧ ក៏គួរស្របតាមគោលការណ៍ដែលបានពិភាក្សាក្នុងកថាខណ្ឌលេខ ១៩.៤ ខាងលើថានីតិវិធីជាតិគួរលឿន មិនលំអៀង ហើយត្រូវបានពិចារណា បែបនេះដោយភាគី ។

*អនុសាសន៍ ៖*

២០.៥ ត្រូវធ្វើវិសោធនកម្មលើមាត្រា ៤៧ ដោយផ្តល់សិទ្ធិជូនកម្មករនិងសហជីពក្នុងការដាក់ពាក្យបណ្តឹងទៅលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសបុគ្គលិក សិទ្ធិឈរឈ្មោះ និងភាពមិនត្រឹមត្រូវនៃការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកជូននាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង ។ ក្នុងករណីដែលបញ្ហានេះមិនអាចដោះស្រាយបានដោយការផ្សះផ្សា វិវាទទាំងនេះត្រូវបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

## ២១. មាត្រា ៥៤ ថ្មី – ភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន

២១.១ មាត្រា ៥៤ ថ្មីកំណត់ពីភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន ។ មាត្រា ៥៤ ថ្មីត្រូវបានផ្លាស់ប្តូរកថាខណ្ឌ "គ" នៃមាត្រា ៥៤ ដោយផ្លាស់ប្តូរតម្រូវការដោយមានសមាជិកដែលមានប័ណ្ណសម្គាល់និងបញ្ជីឈ្មោះសមាជិកត្រឹមត្រូវច្រើនជាងគេទៅនឹងតម្រូវការមានបញ្ជីសមាជិកដែលបានកាត់ប្រាក់ភាគទានច្រើនជាងគេ ។ មាត្រា ៥៤ ថ្មីនៅតែផ្តល់សិទ្ធិផ្តាច់មុខជូនសហជីពដែលមានភាពជាតំណាងបំផុតសម្រាប់គោលបំណងនៃដោះស្រាយវិវាទការងាររួម ។

២១.២ ក្រុមសហជីពបានស្នើសុំឱ្យដកចេញពាក្យ "ដោះស្រាយវិវាទការងាររួម" ពីមាត្រា ៥៤ ។ ការផ្តល់សិទ្ធិផ្តាច់មុខសម្រាប់គោលបំណងដោះស្រាយវិវាទការងាររួមដូនសហជីពដែលមានភាពជាតំណាងបំផុតគឺជាការរំលោភបំពានច្បាស់ណាស់លើស្តង់ដារការងារអន្តរជាតិ ។[75] ខាង CEACR កន្លងមកក៏បានស្នើសុំផ្ទាល់ឱ្យរាជរដ្ឋាភិបាលធ្វើវិសោធនកម្មលើច្បាប់ស្តីពីសហជីព "ដើម្បីធានាថាសហជីពដែលគ្មានភាពជាតំណាងបំផុតមិនត្រូវបានដកហូតមធ្យោបាយចាំបាច់ដើម្បីការពារផលប្រយោជន៍ការងាររបស់សមាជិករបស់ខ្លួន ដូចជាតំណាងក្នុងនាមពួកគាត់ ហើយធ្វើជាតំណាងក្នុងបណ្តឹងរបស់ពួកគាត់ ។"[76]

២១.៣ យោងតាមកថាខណ្ឌ "គ" នៃមាត្រា ៥៤ ថ្មី សហជីពដែលចង់សុំភាពជាតំណាងបំផុតត្រូវមានបញ្ជីសមាជិកដែលបានកាត់ប្រាក់ភាគទានច្រើនជាងគេ ។ បញ្ជីនេះត្រូវដាក់ទៅនាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈយោងតាមបទប្បញ្ញត្តិនៃប្រកាសលេខ ៣០៣/១៨ ។[77] នៅក្នុងករណីមុនៗ ខាង CFA បានរកឃើញថាតម្រូវការឱ្យដាក់បញ្ជីសមាជិកសម្រាប់គោលបំណងកំណត់ពីភាពជាតំណាងអាចផ្ទុយទៅនឹងស្តង់ដារការងារអន្តរជាតិ ។[78] ការដាក់បញ្ជីបែបនេះអាចធ្វើឱ្យអំពើរើសអើងសហជីពកើតមានស្រួលជាងមុន ហើយធ្វើឱ្យសមាជិកងាយរងគ្រោះចំពោះការគំរាមកំហែងនិងការបំភិតបំភ័យដើម្បីបង្ខំឱ្យពួកគាត់លាឈប់ពីសហជីពដើម្បីធ្វើឱ្យខូចដល់ពាក្យសុំភាពជាតំណាងបំផុត ។

២១.៤ ក្នុងករណីមុនៗ ខាង CFA បានសម្រេចថាការសម្រេចលើពាក្យសុំភាពជាតំណាងបំផុតគួរផ្អែកលើការបោះឆ្នោតរបស់កម្មករនិយោជិត ។[79] ទោះបីជាមាត្រា ៥៤ ថ្មី (និងបទប្បញ្ញត្តិពាក់ព័ន្ធនៃប្រកាសលេខ ៣០៣/១៨) ចែងអំពីការបោះឆ្នោតដើម្បីសម្រេចពីភាពជាតំណាងបំផុត ក៏មានបទប្បញ្ញត្តិដែលឱ្យមានការសម្រេចលើភាពជាតំណាងបំផុតដោយគ្មានការបោះឆ្នោតរបស់កម្មករនិយោជិតផងដែរ ។ ឧទាហរណ៍ បើសិនជាសហជីពមានសមាជិកច្រើនជាង ៣០ ភាគរយនៃកម្មករនិយោជិតសរុបនៅក្នុងសហគ្រាសឬគ្រឹះស្ថានដែលមានតែសហជីពមួយ ក្នុងករណីនេះច្បាប់មិនតម្រូវឱ្យមានការបោះឆ្នោតរបស់កម្មករនិយោជិតទេ ។ ទោះយ៉ាងណាក៏ដោយ នៅតែគួរមានការបោះឆ្នោតសម្ងាត់ដើម្បីរកឃើញថាតើសហជីពនោះពិតជាតំណាងឱ្យកម្មករនិយោជិតភាគច្រើននៅក្នុងសហគ្រាសឬគ្រឹះស្ថានឬទេ ។

*អនុសាសន៍ ៖*

២១.៥ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៥៤ ដោយដកចេញសិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទរួម។ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៥៤ និងប្រកាសលេខ ៣០៣/១៨ ដោយដកចេញតម្រូវការក្នុងការដាក់បញ្ជីឈ្មោះសមាជិក ។ ត្រូវធ្វើវិសោធនកម្មលើកថាខណ្ឌ គ នៃមាត្រា ៥៤ រួមទាំងប្រការពាក់ព័ន្ធនៅក្នុងប្រកាសលេខ ៣០៣/១៨ ដើម្បីតម្រូវអោយមានការបោះឆ្នោតពីកម្មករនិយោជិតទាំង

អស់ ដើម្បីឱ្យនិយោជកស្វែងរកការគាំទ្រពីកម្មករនិយោជិតសរុបក្នុងសហគ្រាស ឬគ្រឹះស្ថានដើម្បីស្វែងរកសហជីពដែលពិតជាមានភាពជាតំណាងបំផុត ។

## ២២. មាត្រា ៥៥ ថ្មី – ភាពជាតំណាងបំផុតក្នុងវិជ្ជាជីវៈមួយឬសកម្មភាពសេដ្ឋកិច្ចមួយឬវិស័យមួយ

២២.១ មាត្រា ៥៥ ថ្មីផ្លាស់ប្តូរលក្ខខណ្ឌដើម្បីទទួលបានភាពជាតំណាងបំផុតក្នុងវិជ្ជាជីវៈមួយឬសកម្មភាពសេដ្ឋកិច្ចមួយឬវិស័យមួយ ។ សហជីពដែលដាក់ពាក្យនៅតែត្រូវអនុវត្តតាមកថាខណ្ឌ "ក" និង "ខ" នៃមាត្រា ៥៤ ថ្មី ហើយក៏ត្រូវមានបញ្ជីសមាជិកដែលបានកាត់ប្រាក់ភាគទានចាប់ពី ៣០ ភាគរយនៃចំនួនកម្មករនិយោជិតទាំងអស់នៅក្នុងវិជ្ជាជីវៈឬសកម្មភាពសេដ្ឋកិច្ចឬវិស័យដែលសហជីពដាក់ពាក្យសុំបញ្ជាក់ភាពជាតំណាងបំផុត ។ មាត្រា ៥៥ ថ្មីនៅតែផ្តល់សិទ្ធិផ្តាច់មុខសម្រាប់គោលបំណងដោះស្រាយវិវាទការងាររួមជូននិយោជក ឬសមាគមនិយោជកនៃវិជ្ជាជីវៈមួយឬសកម្មភាពសេដ្ឋកិច្ចមួយឬវិស័យមួយ ។

២២.២ ក្រុមសហជីពបានស្នើសុំដកចេញពាក្យ "ដោះស្រាយវិវាទការងាររួម" ពីមាត្រា ៥៥ ។ គោលការណ៍ដែលបានពិភាក្សាតាមមាត្រា ៥៤ ថ្មីខាងលើពាក់ព័ន្ធវិវាទការងាររួម រួមទាំងការដាក់បញ្ជីសមាជិកដែលបានកាត់ប្រាក់ភាគទាន ក៏ត្រូវអនុវត្តចំពោះមាត្រា ៥៥ ថ្មីផងដែរ ។

*អនុសាសន៍ ៖*

២២.៣ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៥៥ ដោយដកចេញសិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួម និងតម្រូវការដាក់បញ្ជីឈ្មោះសមាជិកដែលបានកាត់ប្រាក់ភាគទាន ។

## ២៣. មាត្រា ៥៦ – សំណើសុំបញ្ជាក់ភាពជាតំណាងបំផុត និងមាត្រា ៥៧ – ការកំណត់ភាពជាតំណាងបំផុតដោយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ

២៣.១ មាត្រា ៥៦ និង ៥៦ មិនត្រូវបានធ្វើវិសោធនកម្មទេ ហើយក្រុមសហជីពក៏មិនបានស្នើសុំឱ្យមានការវិសោធនកម្មលើមាត្រា ៥៦ ឬ ៥៧ ទេ ។

២៣.២ មាត្រា ៥៦ តម្រូវឱ្យសហជីពសំណើសុំបញ្ជាក់ភាពជាតំណាងបំផុតពីក្រសួងទទួលបន្ទុកវិស័យការងារតាមបែបបទនិងនីតិវិធីដែលមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ដែលបច្ចុប្បន្នកំណត់ដោយប្រកាសលេខ ៣០៣/១៨ ។ មាត្រា ៥៧ តម្រូវឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រេចពីភាពជាតំណាងបំផុតក្នុងរយៈពេល ៣០ ថ្ងៃក្រោយពេលបានទទួលការសំណើសុំ ។

២៣.៣ ក្នុងករណីមុនៗ ខាង CFA បានលើកឡើងថាការបញ្ជាក់ពីភាពជាតំណាងបំផុតគួរធ្វើដោយស្ថាប័នឯករាជ្យ[80] ហើយបញ្ជាក់តាមរយៈការបោះឆ្នោតរបស់កម្មករនិយោជិត ហើយសហជីពដែលខកខានមិនបានទទួលសំឡេងគាំទ្រច្រើនគ្រប់គ្រាន់មិនបានជាប់ឆ្នោតត្រូវមានសិទ្ធិក្នុងការស្នើសុំបោះឆ្នោតថ្មីបន្ទាប់ពីរយៈពេលកំណត់[81]។ ខណៈនីតិវិធីសម្រាប់ការបោះឆ្នោតសម្ងាត់ដើម្បីបញ្ជាក់ពីភាពជាតំណាងបំផុត[82] និងសិទ្ធិរបស់សហជីពភាគតិចក្នុងការតវ៉ាទៅនឹងភាពជាតំណាងបំផុតរបស់សហជីពផ្សេងបន្ទាប់ពីរយៈពេលកំណត់[83] រួចហើយ មាត្រា ៥៦ និង ៥៧នៅតែកំណត់ថាភាពជាតំណាងបំផុតត្រូវបញ្ជាក់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយមិនបញ្ជាក់ដោយស្ថាប័នឯករាជ្យទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺជាស្ថាប័នមួយដែលទទួលស្គាល់ជាអន្តរជាតិថាជាស្ថាប័នឯករាជ្យនិងមិនលំអៀង ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺជាស្ថាប័នមួយដែលរាជរដ្ឋាភិបាលអាចផ្តល់អំណាចបំពេញមុខងារនេះបាន ។

*អនុសាសន៍ ៖*

២៣.៤ ត្រូវធ្វើវិសោធនកម្មលើមាត្រា ៥៦ និងមាត្រា ៥៧ ដោយផ្ទេរកាតព្វកិច្ចបញ្ជាក់ភាពជាតំណាងបំផុតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈជូនស្ថាប័នឯករាជ្យដូចជាក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

# ២៤. មាត្រា ៥៩ ថ្មី – សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាសឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុត

២៤.១ មាត្រា ៥៩ ថ្មីបានបញ្ចូលកថាខណ្ឌថ្មី គឺកថាខណ្ឌ "ឈ" ដែលបើកសិទ្ធិឱ្យសហជីពដែលមានភាគតិចនៅក្នុងសហគ្រាសឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុតធ្វើជាតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទការងាររួមដែលមិនកើតចេញពីការអនុវត្តអនុសញ្ញារួម ។ សហជីពដែលរំលោភលើមាត្រា ៥៩ ថ្មីត្រូវទទួលការព្រមានហើយក្រោយមកត្រូវទទួលពិន័យជាប្រាក់មិនលើសពី ៥.០០០.០០០ រៀល (ប្រមាណ ១២៣០ ដុល្លារអាមេរិច) យោងតាមមាត្រា ៨៦ នៃច្បាប់ស្តីពីសហជីព ។

២៤.២ ក្រុមសហជីពបានស្នើសុំឱ្យធ្វើវិសោធនកម្មលើមាត្រា ៥៩ ដោយធ្វើវិសោធនកម្មលើកថាខណ្ឌ "គ" មិនមែនលើកថាខណ្ឌបន្ថែមថ្មី"ឈ"ទេ ដើម្បីបើកសិទ្ធិឱ្យសហជីពដែលមានភាគតិចធ្វើជាតំណាងសមាជិករបស់ខ្លួនក្នុងការដោះស្រាយវិវាទបុគ្គល ឬវិវាទការងាររួម ហើយនិងសិទ្ធិផ្សេងៗដែលកំណត់ដោយច្បាប់ ។

២៤.៣ ដូចបានពិភាក្សានៅក្នុងកថាខណ្ឌលេខ ២១.២ ខាងលើ ការរារាំងសហជីពដែលមានភាគតិចពីការធ្វើជាតំណាងសមាជិករបស់ខ្លួនក្នុងការដោះស្រាយវិវាទការងាររួមផ្ទុយទៅនឹងស្តង់ដារការងារអន្តរជាតិ[84] និង CEACR កន្លងមកក៏បានស្នើសុំផ្ទាល់ឱ្យរាជរដ្ឋាភិបាលចាត់វិធានការដើម្បីធានាថាសហជីពដែលមានភាគតិចមានត្រូវបានដកហូតសមត្ថភាពក្នុងការតំណាងក្នុងនាមសមាជិក និងធ្វើជាតំណាងសមាជិកក្នុងករណីបណ្តឹង (ឧ. នៅក្នុងសវនការក្រុមប្រឹក្សាអាជ្ញាកណ្តាល) ។[85]

*អនុសាសន៍ ៖*

២៤.៤ ត្រូវធ្វើវិសោធនកម្មបន្ថែមទៀតលើមាត្រា ៥៩ ដោយផ្តល់សិទ្ធិជូនសហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស ឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុតក្នុងការធ្វើជាតំណាងសមាជិករបស់ខ្លួនក្នុងវិវាទទាំងបុគ្គលទាំងរួម ។

## ២៥. មាត្រា ៦២ – ការមិនរើសអើងដោយសារតែសកម្មភាពរបស់សហជីព និង មាត្រា ៦៣ – សកម្មភាពរបស់និយោជកដែលចាត់ទុកជាអនុវត្តមិនត្រឹមត្រូវ

២៥.១ មាត្រា ៦២ និង ៦៣ មិនត្រូវបានធ្វើវិសោធនកម្មទេ ហើយក្រុមសហជីពក៏មិនបានស្នើសុំឱ្យមានការវិសោធនកម្មលើមាត្រា ៦២ ឬ ៦៣ ទេ ។

២៥.២ មាត្រា ៦២ ចែងថា និយោជកមិនត្រូវរើសអើងដោយយកលេសដោយឈរលើមូលដ្ឋាននៃការចូលរួមការកាន់តំណែងឬជាថ្នាក់ដឹកនាំរបស់សហជីព ឬការចូលរួមរបស់កម្មករនិយោជិតក្នុងសកម្មភាពសហជីពដើម្បីធ្វើជាការសម្រេចចិត្តក្នុងរឿងមួយចំនួនរួមបញ្ចូលការបញ្ចប់កិច្ចសន្យាការងារដែលរួមបញ្ចូលទាំងការបញ្ឈប់ ឬការមិនបន្តកិច្ចសន្យាការងារដែលមានជាបន្តគ្នាដោយខុសនីតិវិធី ។

២៥.៣ មាត្រា ៦៣ កំណត់ការអនុវត្តមួយចំនួនដោយនិយោជកត្រូវចាត់ទុកជាការអនុវត្តការងារមិនត្រឹមត្រូវហើយក៏ខុសច្បាប់ដែរ ។ ក្នុងចំណោមការអនុវត្តនេះមានកថាខណ្ឌ "ខ" ដែលចែងថាជាការអនុវត្តការងារមិនស្មើភាពដោយការដាក់ចេញនូវលក្ខខណ្ឌការងារ ឬការបន្តធ្វើការងារដែលតម្រូវឱ្យបុគ្គល

នោះមិនត្រូវចូលរួមក្នុងសហជីព ឬដកខ្លួនចេញពីសហជីពដែលខ្លួនជាសមាជិកត្រូវចាត់ទុកថាការអនុវត្តការងារមិនត្រឹមត្រូវដោយនិយោជក ។

២៥.៤ ក្នុងករណីមុនៗពាក់ព័ន្ធនឹងប្រទេសកម្ពុជា ខាង CFA បានលើកឡើងពីការព្រួយបារម្ភទាក់ទងការប្រើប្រាស់កិច្ចសន្យាការងារដែលមានថិរវេលាកំណត់ក្នុងគោលបំណងប្រឆាំងសហជីព ហើយនិងរបៀបការប្រើប្រាស់រយៈពេលវែងនៃ FDC អាចជារបាំងសម្រាប់ការប្រើប្រាស់សិទ្ធិសហជីពដោយសេរីភាពពេញលេញ ។[86] ខាង CFA ក៏បានបញ្ជាក់ជាថ្មីអំពីគោលការណ៍មូលដ្ឋាននៃសេរីភាពនៃការបង្កើតសមាគមថាកម្មករនិយោជិតគួរមានការការពារសមស្របប្រឆាំងនឹងការរើសអើងសហជីពទាំងអស់ពាក់ព័ន្ធនឹងការងាររបស់ខ្លួន ។[87] ទោះយ៉ាងណាក៏ដោយ ខាង CFA ក៏បានទទួលស្គាល់ថាកម្មករនិយោជិតមានការលំបាកក្នុងការបង្ហាញបណ្តឹងក្នុងការរើសអើងសហជីពនៅក្នុងប្រទេសកម្ពុជា ហើយបានស្នើថាការលំបាកនេះអាចបន្ធូរបន្ថយបានដោយតម្រូវឱ្យនិយោជកបង្ហាញភស្តុតាងបញ្ជាក់ថាការសម្រេចបញ្ឈប់កម្មករនិយោជិតមិនមានទំនាក់ទំនងជាមួយនឹងសកម្មភាពសហជីពរបស់កម្មករនិយោជិតនោះ[88]។ ជាពិសេសចំពោះកម្មករនិយោជិតដែលមាន FDC ដែលទទួលបានការការពារតិចតួចណាស់ពីច្បាប់ប្រឆាំងនឹងការមិនបន្តកិច្ចសន្យាការងាររបស់ពួកគាត់ ហើយតាមស្ថានភាពជាក់ស្តែងតើនរណាដែលកំពុងទទួលបន្ទុកភស្តុតាងបង្ហាញថាការមិនបន្តកិច្ចសន្យាបានកើតឡើងដោយសារតែការរើសអើងសហជីព ។

២៥.៥ ទោះបីជាខាង CEACR បានទទួលស្គាល់ថាមាត្រា ៦៣ នៃច្បាប់ស្តីពីសហជីពចែងថាការមិនបន្តកិច្ចសន្យាការងារដោយសារតែការរើសអើងសហជីពត្រូវចាត់ទុកថាអនុវត្តការងារមិនត្រឹមត្រូវ[89] កម្មករនិយោជិតដែលមាន FDC នៅតែមានការលំបាកខ្លាំងណាស់ក្នុងការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបង្កើតសមាគមរបស់ខ្លួន។ ជាពិសេសសម្រាប់កម្មករនិយោជិតដែលមាន FDC ហើយដែលហ៊ានឈរជាថ្នាក់ដឹកនាំសហជីពមូលដ្ឋានឯករាជ្យ។ ឧទាហរណ៍ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ សហជីពមូលដ្ឋាននៃសហព័ន្ធសហជីពកម្ពុជានៅក្រុមហ៊ុន ជី ដាប់បែលយូ ហ្វ្រីនវេ ថេកស្តាយ ឯ.ក បានជូនដំណឹងដល់អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនអំពីកាលបរិច្ឆេទ និងទីកន្លែងការបោះឆ្នោតបង្កើតសហជីពមូលដ្ឋាននៅក្នុងក្រុមហ៊ុន ។[90] នៅថ្ងៃទី ២២ ខែមករាឆ្នាំ ២០១៩ លទ្ធផលនៃការបោះឆ្នោតនោះត្រូវបានបញ្ជូនទៅរោងចក្រ។[91] នៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៩ យោងតាមលិខិតជូនដំណឹងនោះមានបេក្ខជន ៧នាក់ ក្នុងចំណោម១១ នាក់ ត្រូវបានក្រុមហ៊ុនប្រាប់បេក្ខជន ៧ នាក់នោះថានិយោជកមិនបន្តកិច្ចសន្យាការងាររបស់ពួកគាត់ទេ ។ ក្នុងចំណោម ៧ នាក់នេះក៏មានប្រធាន អនុប្រធាន លេខាធិការ និងហេរញ្ញិកនៃសហជីពមូលដ្ឋាន ។ ជាធម្មតាកម្មករទាំងនេះត្រូវទទួលការពារពីការបញ្ឈប់ដោយគ្មានការយល់ព្រមពីអធិការការងារតាមមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព ពីព្រោះកម្មករនិយោជិតទាំងនេះមាន FDC ស្របតាមច្បាប់(ដោយពួកគាត់បានធ្វើការតិចជាង ២ ឆ្នាំនៅក្នុងរោងចក្រ) ហើយដោយមូលហេតុនេះ នាយកដ្ឋានវិវាទការងារបានសម្រេចថាករណីរបស់ពួកគាត់គឺជា

ករណីមិនបន្តកិច្ចសន្យាការងារ ហើយមិនមែនករណីបញ្ចប់កិច្ចសន្យាការងារទេ[92]។ ដូច្នេះ នាយកដ្ឋានបានសម្រេចចិត្តថាមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពមិនអាចអនុវត្តចំពោះករណីរបស់ពួកគាត់បានទេ ។

*អនុសាសន៍ ៖*

- **២៥.៦** ត្រូវធ្វើវិសោធនកម្មលើមាត្រា ៦២ និងមាត្រា ៦៣ ដោយផ្តល់ការការពារបន្ថែមទៀតជូនសមាជិក សកម្មជន និងថ្នាក់ដឹកនាំសហជីពដែលមានកិច្ចសន្យាការងារដែលមានថិរវេលាកំណត់ដើម្បីឆ្លើយតបទៅនឹងការព្រួយបារម្ភដែលខាង CFA បានលើកឡើងនៅក្នុងករណីពាក់ព័ន្ធនឹងកម្ពុជាអំពីការប្រើប្រាស់កិច្ចសន្យាការងារបែបនេះក្នុងរយៈពេលយូរក្នុងគោលបំណងធ្វើអោយចុះខ្សោយនិងរារាំងសហជីព ។ ច្បាប់អាចផ្តល់ការការពារនេះដោយផ្ទេរបន្ទុកនៃការភស្តុតាងក្នុងករណីមិនបន្តកិច្ចសន្យាពីកម្មករនិយោជិតជូនទៅនិយោជកនិងតម្រូវឱ្យនិយោជកផ្តល់ភស្តុតាងបង្ហាញវិញថាថាកិច្ចសន្យាការងាររបស់កម្មករនិយោជិតមិនត្រូវបានបន្តសារជាថ្មីដោយមូលហេតុក្រៅពីជាសមាជិកឬការចូលរួមក្នុងសកម្មភាពសហជីពឡើយ។

# ២៦. មាត្រា ៦៧ – ការការពារចំពោះការបញ្ឈប់ពីការងារ

២៦.១ មាត្រា ៦៧ មិនត្រូវបានធ្វើវិសោធនកម្មទេ ។

